គណៈកម្មាធិការ ជើម្បីការបោះឆ្នោត ដោយសេរី និងយុត្តិធម៌ នៅកម្ពុជា

របាយការណ៍

សង្ខេបក្រោយពេលបោះឆ្នោតលើកទី១

រយៈពេល ៧ ខែ

(គិតពី ខែតុលា ឆ្នាំ២០០៣ ដល់ ខែមេសា ឆ្នាំ២០០៤)

ខែឧសភា ឆ្នាំ២០០៤

មាតិកា **ទំព័រ**

ក- សេចក្តីសង្ខេបសំខាន់ៗនៃការសង្កេត ១-៤

ខ- សង្ខេបពតីមានជាក់ស្តែងសំខាន់ៗទាក់ទិនសមាជិកសភា ៥

គ- តារាងសង្ខេបការបំពេញតួនាទី និងភារកិច្ចរបស់សភា ៦-៧

ឃ- សកម្មភាពទំនាក់ទំនងជាមួយ ប្រជាពលរដ្ឋ និងរដ្ឋាភិបាល ៨-១២

ង- ចំណេីរការចរចាបង្កើតរដ្ឋាភិបាលថ្មី ១៣-១៤

ច- ស្ថានភាពគំរាមកំហែង បំភ័យបំភ័យ និងឃាតកម្ម ១៤-១៥

ឆ- អត្ថុសាសន៏ ១៥

<u>ឧបសម្ព័ន្ធ ១:</u> វិធីសាស្ត្រ និងការលំបាកក្នុងការសង្កេត ១៦-១៨

<u>ឧបសម្ព័ន្ធ ២:</u> កាលប្បវត្តិ នៃចំណេីរការចរចា ១៩-៣០

<u>ឧបសម្ព័ន្ធ ៣:</u> របាយការណ៏លំអិត ស្តីពីសកម្មភាពរបស់សភា ៣១-៤៣

<u>ឧបសម្ព័ន្ធ ៤:</u> របាយការណ៏ ស្តីពីការគំរាមកំហែង និងឃាតកម្ម ៤៤-៥៦

<u>ឧបសម្ព័ន្ធ ៥:</u> បញ្ជីតំណាងរាស្ត្រ ការផ្ទាស់ប្តូរ និងតំណាងរាស្ត្រស្នេី ៥៧-៦៤

<u>ឧបសម្ព័ន្ធ ៦:</u> ទម្រង់សង្កេតការណ៏ និងលិខិតផ្សេងៗ ៦៥-៧៣

ក. សេចក្តីសង្ខេបសំខាន់ៗនៃការសង្កេត

គណៈកម្មាធិការខុមប្រែល្វ បាននិងកំពុងសង្កេតសភាពការណ៍ក្រោយពេលបោះឆ្នោតសភាជាតិអណត្តិទី៣ ជាពិសេសលើដំណើរការចរចាដើម្បីបង្កើតរាជរដ្ឋាភិបាល និងដំណើរការរបស់រដ្ឋសភា និងសកម្មភាពរបស់តំណាងរាស្ត្រ។ ក្នុងកំឡុងពេលប្រាំពីរ (៧)ខែ ដោយគិតចាប់តាំងពី ខែតុលា ឆ្នាំ២០០៣ ដល់ខែមេសា ឆ្នាំ២០០៤នេះ **ខុមប្រែល្វ** បានរកឃើញចំនុចសំខាន់ៗ នៅក្នុងរបាយការណ៍នៃការសង្កេតដូចខាងក្រោម:

១- *ក្រោយពេលបោះឆ្នោតលើកនេះ មានបរិយាកាសនយោបាយប្រសើរឡើង បើប្រៀបធៀបទៅនឹងបរិយាកាសក្រោយពេលបោះឆ្នោតឆ្នាំ១៩៩៨ ប៉ុន្តែបរិយាកាសនយោបាយ **"មិនទាន់ទុកចិត្តគ្នាក្នុងចំណោមគណបក្សនយោបាយនានា"** បន្តនៅមាននៅឡើយ។* ការកើតមានទំនាស់នយោបាយ និងបន្ថែមសភាព-ការណ៍ នៅមានករណីបំភិតបំភ័យ គំរាមកំហែង និងឃាតកម្ម បានបង្កឱ្យមានការជះឥទ្ធិពលទៅលើដំណើរការចរចារៀបចំរចនាសម្ព័ន្ធរដ្ឋសភា និងបង្កើតរាជរដ្ឋាភិបាល ដែលប្រើអស់ពេលច្រើន (សូមមើលកាលប្បវត្តិក្នុង **ឧបសម្ព័ន្ធ ២**)។ ទំនាស់នយោបាយនោះ គឺនិយាយទៅដល់ទំនាស់លើដំណើរការបោះឆ្នោត ពិសេសស្ថាប័នរៀបចំការបោះឆ្នោត និងនៅក្រោយពេលបោះឆ្នោត គណបក្សនយោបាយមិនទាន់អស់ចិត្តចំពោះដំណោះស្រាយលើពាក្យបណ្តឹងអំពីភាពមិនប្រក្រតីនៃដំណើរការបោះឆ្នោត (យោងរបាយការណ៍ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០០៣ របស់ខុមប្រែល្វ)។

បើទោះបីបរិយាកាសនៃទំនាស់ពេលបោះឆ្នោត និងដំណើរការចរចា មានការថយចុះអំពើហិង្សាធ្ងន់ធ្ងរទាក់ទិនគណបក្សនយោបាយ ប៉ុន្តែក្នុងកំឡុងពេលដំបូងនៃដំណើរការចរចា មានការប្តឹងផ្តល់គ្នាទៅវិញទៅមកវាំងមេដឹកនាំគណបក្សជាប់ឆ្នោត។ យ៉ាងហោចណាស់ មានពត៌មាននៃករណីគំរាមកំហែងចំនួន ៥ករណី ទាក់ទិននឹងជនរងគ្រោះជាសមាជិកសភា និងមានអំពើឃាតកម្ម ១៧ករណី និងអំពើគំរាមកំហែង ១៤ករណីទាក់ទិននឹងសកម្មជនគណបក្សនយោបាយ។ ដោយឡែក ករណីឃាតកម្មធំៗចំនួនបីដែលបានកើតឡើង នៅកណ្តាលរាជធានីភ្នំពេញ ព្រមទាំងបង្កឱ្យមានការភ័យខ្លាចខ្លាំងនោះគឺ:

- ករណីបាញ់សម្លាប់ **លោក ជូរ ជេត្តាវិទ្ធ** អតីតអ្នកនិពន្ធអត្ថបទពត៌មានឱ្យវិទ្យុតារាព្រហ្ម ដែលគាំទ្រគណបក្សហ៊្វុនស៊ិនប៉ិច នាថ្ងៃទី ១៨ តុលា ២០០៣។
- ករណីបាញ់ប្រហារ អតីតតារាចម្រៀងដ៏មានប្រជាប្រិយភាព **កញ្ញា ទូច ស៊ុននិច** និងម្តាយ នាថ្ងៃទី ២១ តុលា ២០០៣។
- ករណីបាញ់សម្លាប់ **លោក ជា វិជ្ជា** អតីតមេដឹកនាំសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា នាថ្ងៃទី ២២ មករា ២០០៤។

ករណីភាគច្រើននៃអំពើគំរាមកំហែង បំភិតបំភ័យ ឃាតកម្មពាក់ព័ន្ធគណបក្សនយោបាយខាងលើ ពុំមានការចាត់វិធាការដោះស្រាយដោយយុត្តិធម៌ ដែលបណ្តាលឱ្យវប្បធម៌និទណ្ឌភាពនៅមានជាបន្ត (សូមមើលតារាងភ្ជាប់ជូនក្នុង **<u>ឧបសម្ព័ន្ធ ៤</u>**)

២- *<u>មានការខិតខំពិភាក្សាយ៉ាងសកម្មដើម្បីរៀបចំកម្មវិធីនយោបាយសំរាប់រាជរដ្ឋាភិបាលថ្មី មុននឹងពិភាក្សាអំពីការបែងចែកអំណាច</u>*។ ចំនុចពិភាក្សាទាំងនោះ ភាគច្រើនបានយកចិត្តទុកដាក់ទៅនឹងកិច្ចសន្យាក្នុងអំឡុងពេលឃោសនាបោះឆ្នោត និងអនុសាសន៍របស់សង្គមស៊ីវិលមួយចំនួន ព្រមទាំងបានផ្តល់ពត៌មានខ្លះៗអំពីដំណើរការចរចាដល់សាធារណជន និងអ្នកសារពត៌មាន។ (សូមមើលពត៌មានលំអិតនៅចំនុច ២) ចំនុចដែលត្រូវបានយកចិត្តទុកដាក់សំខាន់ៗទាំងនោះមានដូចជា:

- អនុម័តច្បាប់ថ្មីដែលជំរុញឱ្យមានតម្លាភាពនិងការទទួលខុសត្រូវ រួមមានច្បាប់ប្រឆាំងអំពើពុករលួយជាដើម។
- ការកែទម្រង់ប្រព័ន្ធយុត្តិធម៌ ដើម្បីធានាឱ្យមានប្រព័ន្ធតុលាការស្អាតស្អំ។
- ការការពារនិងដោះស្រាយបញ្ហាឯករាជ្យ អធិបតេយ្យភាព បូរណភាពទឹកដី។
- ការអនុវត្តន៍ច្បាប់ស្តីពីសញ្ជាតិ និងច្បាប់ស្តីពីអន្តោប្រវេសន៍ឱ្យមានប្រសិទ្ធភាព។
- ការតម្លើងប្រាក់ប្រៃវត្សជូនមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ និងកម្មករនិយោជិត។
- ការគ្រប់គ្រងប្រើប្រាស់ធនធានធម្មជាតិរួមមាន ព្រៃឈើ ជលផលជាដើម។
- ការបង្កើតឱ្យមានដំណើរការស្ថាប័នឯករាជ្យថ្មីដូចជា គណៈកម្មាធិការជាតិសិទ្ធិមនុស្ស គណៈកម្មាធិការប្រឆាំងអំពើពុករលួយជាដើម និងពង្រឹងស្ថាប័នជាតិដូចជា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។
- ពង្រឹងអំណាចនីតិបញ្ញត្តិ ដើម្បីត្រួតពិនិត្យការងាររបស់រដ្ឋាភិបាល។

៣- *<u>សភាទទួលរងឥទ្ធិពលខ្លាំងពីគណបក្សនយោបាយ និងអ្នកដឹកនាំគណបក្ស</u>*។ ក្នុងនោះរួមមានការបែងចែកអំណាចមិនច្បាស់រវាងគណបក្សនយោបាយ រដ្ឋាភិបាល និងរដ្ឋសភា។ យោងតាមស្មារតីមាត្រា ៨២ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានចែងថា: *"រដ្ឋសភាបើកសម័យប្រជុំដំបូង ហុកសិបថ្ងៃយ៉ាងយូរក្រោយពេលបោះឆ្នោតតាមការកោះប្រជុំរបស់ព្រះមហាក្សត្រ។...រដ្ឋសភាត្រូវអនុម័តបទបញ្ជាផ្ទៃក្នុង..."* គេសង្កេតឃើញថាតំណាងរាស្ត្រជាប់ថ្មីទាំងនោះមិនទាន់បានអនុវត្តតាមតួនាទីភារកិច្ច បានពេញលេញនៅឡើយទេ។ ការមិនអាចដំណើរការការងាររបស់ខ្លួនមកដល់បច្ចុប្បន្ននេះ គឺដោយសារមានឥទ្ធិពលគណបក្សនយោបាយ ដែលមានឧទាហរណ៍ដូចជា:

ពេលបើកសម័យប្រជុំដំបូង តំណាងរាស្ត្រគណបក្សហ៊្វុនស៊ិនប៉ិច និងគណបក្សសមរង្ស៊ីមិនបានចូលរួមដោយសារគណបក្សទាំងពីរប្រកាសមិនព្រមចូលរួមប្រជុំ។ ក្រោយមកគណបក្សហ៊្វុនស៊ិនប៉ិច និងគណបក្សសមរង្ស៊ី ទាមទារឱ្យមានការរៀបចំរចនាសម័ន្ធរដ្ឋសភាថ្មី និងធ្វើបទបញ្ជាផ្ទៃក្នុងសំរាប់រដ្ឋសភា ប៉ុន្តែគណបក្សប្រជាជនកម្ពុជាបែរជាមិនព្រម ដោយទាមទារឱ្យមាន "ការបោះឆ្នោតជាកញ្ចប់" សំរាប់រចនាសម័ន្ធរដ្ឋសភា និងរាជរដ្ឋាភិបាលថ្មីជាមួយគ្នា (ដែលជាការប្រាសចាកទាំងស្រុងទៅនឹងស្មារតីរដ្ឋធម្មនុញ្ញ មាត្រា ៨២ និងមាត្រា១១៩ថ្មី)។ រហូតមកដល់ពេលនេះ សមាជិកសភាពុំទាន់មានរៀបចំការប្រជុំដើម្បីធ្វើបទបញ្ជាផ្ទៃក្នុង និងរៀបចំរចនាសម័ន្ធរបស់ខ្លួនបាននៅឡើយទេ។

- ច្បាប់ផ្តល់អំណាចឥទ្ធិពលខ្លាំងទៅឱ្យគណបក្សនយោបាយចំពោះតំណាងរាស្ត្រ។ ស្មារតីមាត្រា១២០នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រចែងថា: *"...ក្នុងករណីដែលសមាជិកគណបក្សនយោបាយមួយលាលែងចេញពីគណបក្សនោះសាមីខ្លួនត្រូវបាត់បង់សមាជិកភាពតំណាងរាស្ត្រដោយស្វ័យប្រវត្តិ។..."* បានធ្វើឱ្យតំណាងរាស្ត្រមានការខ្លាចរអាក្នុងការបញ្ចេញមតិយោបល់ ឬធ្វើសកម្មភាពផ្សេងៗ ដែលខុសពីមតិយោបល់របស់ថ្នាក់ដឹកនាំ ឬផលប្រយោជន៍គណបក្ស។

ស្មារតីនៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៥១ វាក្យខ័ណ្ឌទី៤ *"អំណាចបែងចែកដាច់ពីគ្នារវាងអំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចនីតិតុលាការ"* ប៉ុន្តែមាត្រា៧៥ វាក្យខ័ណ្ឌទី១ បានធ្វើឱ្យមានភាពមិនដាច់ស្រេចរវាងអំណាចនីតិបញ្ញត្តិ និងអំណាចនីតិប្រតិបត្តិ ដូចជាសមាជិកសភាថ្មីចំនួន ៣០រូប យ៉ាងតិចមានមុខតំណែងជាសមាជិករាជរដ្ឋាភិបាលបច្ចុប្បន្នផងដែរ។

៤- *<u>សកម្មភាពរបស់សមាជិកសភាក្នុងការទទួលខុសត្រូវចំពោះប្រជាពលរដ្ឋនៅមានកំរិត។</u>* ដោយសកម្មភាពសមាជិកសភាមួយចំនួន បានចុះជួបទំនាក់ទំនងជាមួយប្រជាពលរដ្ឋ និងជួយធ្វើអន្តរាគមន៍ ដោះស្រាយបញ្ហានៅតាមមណ្ឌលនានា ប៉ុន្តែសមាជិកសភាភាគច្រើនបានធ្វើសកម្មភាពនៅមានកំរិតក្នុងការឆ្លើយតបតាមសេចក្តីត្រូវការ ឬបញ្ហាពិតប្រាកដនៅក្នុងមណ្ឌលរបស់ខ្លួននៅឡើយទេ។ បើទោះបីគ្មានរចនាសម័ន្ធគ្មានដំណើរការប្រជុំផ្លូវការរបស់សភា និងគ្មានថវិកាសំរាប់ប្រាក់បំណាច់ក៏ដោយ ក៏មានសមាជិកសភាជាប់ឆ្នោតថ្មីចំនួន ៤៦រូប (ស្មើនឹង៣៧%នៃតំណាងរាស្ត្រជាប់ឆ្នោតសរុប ១២៣) នៃគណបក្សជាប់ឆ្នោតទាំងបីបាននឹងកំពុងធ្វើសកម្មភាពទំនាក់ទំនងជាមួយប្រជាពលរដ្ឋម្ខាស់ឆ្នោត និងបានបញ្ចេញមតិយោបល់ផ្តល់អនុសាសន៍នានា។ តំណាងរាស្ត្រគណបក្សសមរង្ស៊ីភាគច្រើន ជាតំណាងរាស្ត្រសកម្មក្នុងការបំពេញតួនាទីជាគណបក្សជំទាស់ (ឬ គណបក្សប្រឆាំង) ដែលបានលើកពីបញ្ហារបស់ប្រជាពលរដ្ឋ និងតិៈទៀនភាពខ្វះខាតរបស់ស្ថាប័ន និងច្បាប់មួយចំនួន។ សមាជិកសភាមកពីគណបក្សនយោបាយទាំងបី ជាពិសេសគណបក្សប្រជាជនកម្ពុជា ធ្វើសកម្មភាពច្រើនចុះទំនាក់ទំនងនៅមូលដ្ឋាន ដែលជាការចុះសួរសុខទុក្ខ ការចុះពង្រឹងគណបក្សនយោបាយ ចែកអំណោយ និងសម្ពោធសមិទ្ធិផលនានា ប៉ុន្តែសកម្មភាពចុះទៅជួយ

ដោះស្រាយបញ្ហារបស់ប្រជាពលរដ្ឋគឺមានតិចតួច ណាស់ត្រឹម១៥លើក ប៉ុណ្ណោះក្នុងចំណោម ១៩០លើក។ (សូមមើលរបាយការណ៍លំអិតនៅចំនុច **ឃ.**១)។

សូមបញ្ជាក់ថា ការិយាល័យអ្នកតំណាងរាស្ត្រស្ទើរតែទាំងអស់មិនទាន់មានដំណើរការសកម្ម ឬពេញលេញដែលអាចឱ្យប្រជាពលរដ្ឋធ្វើទំនាក់ទំនងបានងាយស្រួលជាមួយតំណាងរាស្ត្រនៅឡើយ។ របាយការណ៍ស្តីពីសកម្មភាពរបស់សមាជិកសភានេះ អាចមិនគ្របដណ្តប់គ្រប់សកម្មភាពទាំងអស់នៃសមាជិកសភានោះទេ។ ព្រោះខុមប្រ៊ែលមានការលំបាកក្នុងការទំនាក់ទំនងពតិមានជាមួយគណបក្ស ក៏ដូចបុគ្គលតំណាងរាស្ត្រដែរ។ (សូមមើលបន្ថែម **ឧបសម្ព័ន្ធ ១** ចំនុចទី ៤)។

៥- *<u>តំណាងរាស្ត្រពុំទាន់បំពេញតួនាទី និងភារកិច្ចជាធរមាន និងមិនទាន់មានប្រសិទ្ធិភាព ទោះបីរដ្ឋធម្មនុញ្ញផ្តល់សិទ្ធិអំណាចក៏ដោយ</u>*។ តួនាទីភារកិច្ចទាំងនោះមានមូលដ្ឋានពីស្មារតីមាត្រា ៨២ និង៨៣ ដែលចែងពីការប្រជុំ ការអនុម័តបទបញ្ជាផ្ទៃក្នុង និងការបោះឆ្នោតជ្រើសរើសរចនាសម្ព័ន្ធរដ្ឋសភា មាត្រា៨៥ ស្តីពីការស្នើសុំការបំភ្លឺពីឥស្សរជន ដោយមានការស្នើសុំពីសមាជិកសភាចំនួនមួយភាគដប់ និងមាត្រា៩០ ដែលទាក់ទងទៅនឹងការអនុម័តថវិកាជាតិជាដើម។ មកដល់ថ្ងៃធ្វើរបាយការណ៍នេះ សមាជិកសភាពុំទាន់បានបំពេញតួនាទី និងភារកិច្ចខាងលើនេះបានពេញលេញនៅឡើយទេ។ សមាជិកសភាខ្លះ បានខិតខំអនុវត្តតួនាទីភារកិច្ចក្នុងមាត្រា ៨៥ និង ១៤១ ប៉ុន្តែលទ្ធផលគឺមិនទាន់មានប្រសិទ្ធិភាព។

ជាឧទាហរណ៍ ករណីក្រុមតំណាងរាស្ត្រនៃគណបក្សសមរង្ស៊ីចំនួន ២១រូប ធ្លាប់បានផ្ញើលិខិតទៅក្រុមប្រឹក្សាធម្មនុញ្ញសុំអោយបកស្រាយមាត្រាខ្លះនៃរដ្ឋធម្មនុញ្ញ ប៉ុន្តែត្រូវបានបដិសេធពីសំណាក់ក្រុមប្រឹក្សាធម្មនុញ្ញ។ (សូមមើលរបាយការណ៍លំអិត នៅចំនុច **ក** និង **<u>ឧបសម្ព័ន្ធ ៣</u>** ចំនុចទី ៦)។

ម្យ៉ាងទៀត ការដាក់សំនួរ ឬអំពាវនាវ ឬអន្តរាគមន៍ របស់តំណាងរាស្ត្រចំនួន ៣០លិខិត ទៅស្ថាប័នពាក់ព័ន្ធ ជាពិសេសស្ថាប័នរដ្ឋាភិបាល ពុំទាន់ត្រូវបានយកចិត្តទុកដាក់ គឺមានន័យថា ភាគច្រើនគ្មានចំលើយ ឬការបកស្រាយពីស្ថាប័នមានសមត្ថកិច្ចទាំងនោះ (សូមមើលរបាយការណ៍លំអិតនៅចំនុច **ឃ.**៤ និង **<u>ឧបសម្ព័ន្ធ ៣</u>** ចំនុចទី ៦)។

ជាសរុបសេចក្តី របាយការណ៍សង្កេតបង្ហាញថា មានការខិតខំចរចា ដើម្បីរៀបចំកម្មវិធីនយោបាយរបស់រដ្ឋាភិបាល ការបង្កើតរាជរដ្ឋាភិបាលថ្មី និងរចនាសម្ព័ន្ធរបស់សភា ប៉ុន្តែបរិយាកាសនៃការចរចានៅមិនទាន់ទុកចិត្តគ្នា។ សភាមិនទាន់បានបំពេញតួនាទី និងភារកិច្ចដូចមានចែងនៅក្នុងរដ្ឋធម្មនុញ្ញជាធរមាន និងប្រសិទ្ធភាពនោះ គឺដោយសារដំណើរការនៃការចរចានៃគណបក្សនយោបាយកំពុងបន្ត។ សមាជិកសភាមួយចំនួនបានកំពុងធ្វើសកម្មភាពនៅតាមមណ្ឌលនានា ប៉ុន្តែសមាជិកសភាភាគច្រើនបានធ្វើសកម្មភាព និងបំពេញការទទួលខុសត្រូវចំពោះ ឬជាតំណាងរបស់ប្រជាពលរដ្ឋនៅមានកំរិត។

ខ. សេចក្តីមានជាក់ស្តែងសំខាន់ៗទាក់ទិនសមាជិកសភា

សមាជិកសភាសំរាប់រដ្ឋសភាអាណត្តិទីបីនេះមាន១២៣រូប ក្នុងនោះមានស្ត្រី១២រូប ស្មើនឹង១០%។ គណបក្សប្រជាជនកម្ពុជាមាន៧៣រូប (ស្ត្រី៦រូប) គណបក្សហ៊្វុនស៊ិនប៉ិចមាន២៦រូប (ស្ត្រី៣រូប) គណបក្សសមរង្ស៊ីមាន២៤រូប (ស្ត្រី៣រូប) នេះបើយោងតាមការប្រកាសរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) នាថ្ងៃទី៣០ សីហា ២០០៣ ស្តីពីលទ្ធផលបេក្ខជនតំណាងរាស្ត្រជាប់ឆ្នោតសំរាប់រដ្ឋសភាជាតិ អាណត្តិទី៣។

បើគិតរហូតមកដល់ដំណាច់ខែមេសា ២០០៤ ចំនួនតំណាងរាស្ត្រជាស្ត្រី មានការកើនឡើងបី (៣) រូបបន្ថែមទៀតដោយសារមានការផ្លាស់ប្តូរ។ ក្នុងនោះ គណបក្សប្រជាជនកម្ពុជាមាន ៨រូប (ថែម២រូប) គណបក្សហ៊្វុនស៊ិនប៉ិចមាន៤រូប (ថែម១រូប) និងគណបក្សសមរង្ស៊ីមានពីរូបដដែល ដូច្នេះចំនួនសរុបគឺ ១៥រូប ស្មើនឹង១២%នៃតំណាងរាស្ត្រសរុប (ប្រភព គ.ជ.ប)។ (សូមមើលបន្ថែមក្នុង **<u>ឧបសម្ព័ន្ធ ៥</u>**)

- មានតំណាងរាស្ត្រចំនួន៩ រូបត្រូវបានផ្លាស់ប្តូរ ក្នុងនោះស្លាប់ដោយសារជំងឺ ពីរ (២) រូបគឺ:
  - ឯកឧត្តម ម៉ាត់ លី អតីតតំណាងរាស្ត្រមណ្ឌលកំពង់ចាម មកពីគណបក្សប្រជាជនកម្ពុជា
  - ឯកឧត្តម គា សាហាន អតីតតំណាងរាស្ត្រមណ្ឌលកែប មកពីគណបក្សប្រជាជនកម្ពុជា
- មានវិសមិតភាពនៃតំណាងរាស្ត្រ ដែលមានចែងក្នុងមាត្រា៧៩នៃរដ្ឋធម្មនុញ្ញ តួយ៉ាង <u>សម្តេច ជា ស៊ីម តំណាងរាស្ត្រ មណ្ឌលភ្នំពេញ និងជាប្រធានព្រឹទ្ធសភាផង</u>។

តំណាងរាស្ត្រជាប់ឆ្នោតថ្មីពុំទាន់ទទួលប្រាក់បំណាច់ និងសោហ៊ុយបេសកកម្មពីរដ្ឋសភានៅឡើយទេ។

គ. តារាងសង្ខេបការបំពេញតួនាទី និងភារកិច្ចរបស់សភាតំណាងរាស្ត្រ ស្របតាមស្មារតីរដ្ឋធម្មនុញ្ញ

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា	ការអនុវត្តន៍ជាក់ស្តែងរបស់រដ្ឋសភា	កំណត់សំគាល់
<u>មាត្រា ៨២:</u> រដ្ឋសភាបើកសម័យប្រជុំដំបូង ហុកសិបថ្ងៃ យ៉ាងយូរក្រោយពេលបោះឆ្នោត តាមការកោះប្រជុំរបស់ព្រះមហាក្សត្រ។	**<u>មានភាពយឺតយ៉ាវ</u>** (បើគិតពីក្រោយថ្ងៃបោះឆ្នោតថ្ងៃទី ២៧ កក្កដា ២០០៣ រយៈពេល ៦០ថ្ងៃ គឺថ្ងៃទី ២៧ កញ្ញា ២០០៣ ជាក់ស្តែងរដ្ឋសភាបើកសម័យប្រជុំសភាដំបូង គឺនៅថ្ងៃទី ១៥ ធ្នូ ២០០៣ ក្រោមអធិបតីភាព ឯកឧត្តម ជា សុទ្ធ ព្រឹទ្ធបុរសសមាជិកសភា ដើម្បីធ្វើការប្រកាសសុពលភាពនៃអណត្តិរបស់សមាជិកសភា។	រដ្ឋមន្ត្រីព្រះបរមរាជវាំង បានចេញលិខិតកោះអញ្ជើញសមាជិកសភាជាប់ឆ្នោតទាំងអស់ ដើម្បីបើកសម័យប្រជុំដំបូងនៅថ្ងៃទី២៧ កញ្ញា ឆ្នាំ២០០៣។ មានតែសមាជិកសភាជាប់ឆ្នោត មកពីគណបក្សប្រជាជនកម្ពុជាចំនួន៧៣រូប ប៉ុណ្ណោះបានចូលរួមក្នុងកិច្ចប្រជុំនេះ។
<u>មាត្រា ៨២:</u> រដ្ឋសភាត្រូវអនុម័តបទបញ្ជាផ្ទៃក្នុងសម្រេចអំពីសុពលភាពនៃអាណត្តិរបស់សមាជិកនិមួយៗ និងត្រូវបោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នានូវប្រធាន អនុប្រធានរដ្ឋសភា ដោយមតិភាគច្រើនពីរភាគបីនៃសមាជិករដ្ឋសភាទាំងមូល។	**<u>មិនទាន់បានធ្វើ</u>**	គណបក្សប្រជាជនកម្ពុជា បានទាមទារឱ្យមានការបោះឆ្នោតជាកញ្ចប់ សំរាប់រៀបចំរចនាសម្ព័ន្ធរដ្ឋសភា និងបង្កើតរាជរដ្ឋាភិបាល។

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា	ការអនុវត្តន៍ជាក់ស្តែងរបស់រដ្ឋសភា	កំណត់សំគាល់
<u>មាត្រា ៨៣:</u> រដ្ឋសភាប្រជុំសាមញ្ញពីរដងក្នុងមួយឆ្នាំ។	**<u>មិនទាន់បានធ្វើ</u>**	យ៉ាងហោចណាស់មានសេចក្តីព្រាងច្បាប់ និងសេចក្តីស្នើច្បាប់ប្រមាណ៤៩ ស្ថិតនៅក្នុងរដ្ឋសភា។ ក្នុងនោះមានសេចក្តីព្រាងច្បាប់ និងសេចក្តីស្នើច្បាប់ចំនួន ៣0 កំពុងស្ថិតនៅឯគណៈកម្មការជំនាញនានារបស់រដ្ឋសភា និងសេចក្តីព្រាងច្បាប់ចំនួន ១៩ ទៀតកំពុងស្ថិតនៅឯគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា។
<u>មាត្រា ៨៩ និង១៤១:</u> តាមការសុំពីសមាជិកចំនួនមួយភាគដប់យ៉ាងតិច រដ្ឋសភាអាចអញ្ជើញ ឥស្សរជនដ៏ឧត្តមណាមួយមកបំភ្លឺរដ្ឋសភា អំពីបញ្ហាដែលមានសារៈសំខាន់ពិសេស។ និងអាចសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យអំពី ធម្មនុញ្ញភាពនៃច្បាប់នោះ។	**<u>បានធ្វើ ប៉ុន្តែពុំទាន់មានប្រសិទ្ធិភាព</u>**	ក្រុមតំណាងរាស្ត្រនៃគណបក្សសមរង្ស៊ីចំនួន ២១រូបធ្លាប់បានធ្វើលិខិតទៅក្រុមប្រឹក្សាធម្មនុញ្ញសុំឱ្យបកស្រាយមាត្រាខ្លះនៃរដ្ឋធម្មនុញ្ញ ប៉ុន្តែត្រូវបដិសេធម្តងហើយម្តងទៀតថាខុសនីតិ ទម្រង់ច្បាប់។ (សូមមើលបន្ថែមចំនុចខ នៃ **<u>ឧបសម្ព័ន្ធ ៣</u>**)
<u>មាត្រា ៩0:</u> រដ្ឋសភាអនុម័តថវិកាជាតិ ផែនការរដ្ឋ ការឱ្យរដ្ឋខ្ចីប្រាក់ពីគេ ការឱ្យរដ្ឋឱ្យប្រាក់គេខ្ចី ការសន្យានានា ផ្នែកហិរញ្ញវត្ថុ និងការបង្កើត និងការលុបចោលពន្ធដារ។	**<u>មិនទាន់បានធ្វើ</u>**	រាជរដ្ឋាភិបាលបច្ចុប្បន្ន បានចុះហត្ថលេខាទទួល និងខ្ចីជំនួយពីរដ្ឋាភិបាលចិន (ដោយមិនទាន់មានការយល់ព្រមពីរដ្ឋសភាជាតិ)។ យោងបទសម្ភាសន៍ ឯកឧត្តម ហោ ណាំហុង រដ្ឋមន្ត្រីការបរទេស ថ្ងៃទី២៥ មេសា ២00៤។

ឃ. សកម្មភាពទំនាក់ទំនងជាមួយប្រជាពលរដ្ឋ និងរដ្ឋាភិបាល និងការអន្តរាគមន៍នានារបស់សមាជិកសភា

១- ការចុះបេសកកម្មរបស់តំណាងរាស្ត្រ

ក្នុងអំឡុងពេលនេះ តំណាងរាស្ត្រជាប់ឆ្នោតថ្មីទាំង១២៣រូប ពុំទាន់ទទួលបាននូវប្រាក់ប្រៀវត្សប្រាក់បេសកកម្ម ហើយរដ្ឋសភាពុំទាន់មានរចនាសម្ព័ន្ធនៅឡើយ ជាកត្តាមួយជះឥទ្ធិពលនាំឱ្យមានភាពអសកម្ម និងមិនដំណើរការបំពេញតួនាទី និងភារកិច្ចរបស់តំណាងរាស្ត្រ។ ទោះបីជាយ៉ាងណាក៏ដោយក្នុងរយៈពេលប្រាំពីរ (៧) ខែ គិតចាប់តាំងពីខែតុលា ២០០៣រហូតមកដល់ខែមេសា ២០០៤នេះ បានបង្ហាញឱ្យឃើញថា មានតែតំណាងរាស្ត្រចំនួន៤៦រូប ប៉ុណ្ណោះ (ស្មើនឹង៣៧%) ក្នុងចំណោមតំណាងរាស្ត្រជាប់ឆ្នោតអាណត្តិទីបីទាំងអស់ចំនួន១២៣រូប បានចុះទៅតាមមណ្ឌលខេត្ត/ក្រុងរៀងៗខ្លួនចំនួន១៨ ដែលរួមមាន១៩០លើក។ ប៉ុន្តែការចុះជួយធ្វើអន្តរាគមន៍ដោះស្រាយបញ្ហារបស់ប្រជាពលរដ្ឋមានចំនួនត្រឹម១៥លើកប៉ុណ្ណោះ។ បញ្ហាទាំងនោះមានដូចជា: ជម្លោះដីធ្លី ស្ពានប្រឡាយ ជីកស្រះ បញ្ចុះតម្លៃអគ្គិសនីជាដើម។

- គោលបំណងនៃការចុះបេសកកម្មនោះរួមមាន:
  - ចុះជួយអន្តរាគមន៍ដោះស្រាយបញ្ហា ដែលកើតឡើងនៅក្នុងមណ្ឌលរបស់ខ្លួនចំនួន១៥លើក។
    ក្នុងនោះ
    - តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាបានចុះចំនួន៧លើក
    - តំណាងរាស្ត្រគណបក្សហ៊្វុនស៊ិនប៉ិចបានចុះចំនួន១ លើក
    - តំណាងរាស្ត្រគណបក្សសមរង្ស៊ីបានចុះចំនួន៧ លើក
  - ចុះជួបសួរសុខទុក្ខ ចែកអំណោយប្រជាពលរដ្ឋ អាជ្ញាធរមូលដ្ឋានផ្តើមការកសាង និងសម្ពោធសមិទ្ធិផលនានា ចំនួន១៣០លើក។
    ក្នុងនោះ
    - តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាបានចុះ ចំនួន៧១ លើក
    - តំណាងរាស្ត្រគណបក្សហ៊្វុនស៊ិនប៉ិចបានចុះចំនួន១០លើក
    - តំណាងរាស្ត្រគណបក្សសមរង្ស៊ីបានចុះចំនួន៤៩លើក
  - ចុះពង្រឹងបណ្តាញ ដោះស្រាយបញ្ហាផ្ទៃក្នុងគណបក្សចំនួន២៨លើក។
    ក្នុងនោះ
    - តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាបានចុះចំនួន៦លើក

- តំណាងរាស្ត្រគណបក្សហ៊ុនស៊ុនប៊ុចបានចុះចំនួន១៤លើក
- តំណាងរាស្ត្រគណបក្សសមរង្ស៊ីបានចុះចំនួន៨លើក

o ចូលរួមក្នុងកិច្ចប្រជុំ ឬវេទិកាពិភាក្សានានាដូចជាវេទិកាសាធារណៈ ដែលរៀបចំឡើងដោយអង្គការក្រៅរដ្ឋាភិបាលចំនួន៨ លើក ។

ក្នុងនោះ

- តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាបានចុះ ចំនួន ១លើក
- តំណាងរាស្ត្រគណបក្សហ៊ុនស៊ុនប៊ុចបានចុះ ចំនួន ៣លើក
- តំណាងរាស្ត្រគណបក្សសមរង្ស៊ីបានចុះ ចំនួន ៤ លើក

o ចុះរឿងផ្ទាល់ខ្លួន ចំនួន៩ លើក (នៃការចុះបេសកកម្មទាំង១៥0 លើក) ។

ក្នុងបេសកកម្មទាំង១៥0 លើក របស់តំណាងរាស្ត្រ **ខុមហ្វ្រែល** មិនបានយកផ្តោតចំពោះបេសកកម្មរឿងផ្ទាល់ខ្លួនរបស់តំណាងរាស្ត្រទេ ដូច្នេះចំនួនបេសកម្មដែលមានសារៈប្រយោជន៍ដល់រាស្ត្រ មានចំនួនតែ១៨១ លើកប៉ុណ្ណោះដែលក្នុងនោះមាន :

- ក្នុងចំណោមតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាជាប់ឆ្នោតចំនួន៧៣នាក់ មានតំណាងរាស្ត្រចំនួន ២៣ នាក់ត្រូវជា៣២% បានចុះបេសកកម្មចំនួន៩១ ដង ទៅមណ្ឌលខេត្ត/ក្រុងរបស់ខ្លួន ។
- ក្នុងចំណោមតំណាងរាស្ត្រគណបក្សហ៊ុនស៊ុនប៊ុចជាប់ឆ្នោតចំនួន២៦នាក់ មានតំណាងរាស្ត្រចំនួន១0 នាក់ត្រូវជា៣៨%បានចុះបេសកកម្មចំនួន៣៤ដង ទៅមណ្ឌលខេត្ត/ក្រុង របស់ខ្លួន ។
- ក្នុងចំណោមតំណាងរាស្ត្រគណបក្សសមរង្ស៊ីជាប់ឆ្នោតចំនួន២៤នាក់ មានតំណាងរាស្ត្រចំនួន១៣នាក់ ត្រូវជា៥៤% បានចុះបេសកកម្មចំនួន៦៥ដង ទៅមណ្ឌលខេត្ត/ក្រុង របស់ខ្លួន ។

(សូមមើលបន្ថែមក្នុង **ឧបសម្ព័ន្ធ ៣** ចំនុចទី២)

២- <u>ការទំនាក់ទំនងរវាងប្រជាពលរដ្ឋ និងតំណាងរាស្ត្រ</u>

ប្រជាពលរដ្ឋនៅបណ្តាខេត្ត/ក្រុងមួយចំនួន បានតួញ្ចែរអំពីការលំបាកក្នុងការធ្វើទំនាក់ទំនងផ្តល់ពតិមាន សុំអន្តរាគមន៍ពីសំណាក់តំណាងរាស្ត្ររបស់ខ្លួន។ បញ្ហាទាំងនោះបណ្តាលមកពី:

- ការិយាល័យតំណាងរាស្ត្រនៅតាមមណ្ឌលខេត្ត/ក្រុងស្ទើរទាំងអស់ពុំមានដំណើរការអ្វីទេ គឺមានតែបុគ្គលិក ម្នាក់ឬពីរនាក់នៅប្រចាំការប៉ុណ្ណោះ ។
- ម្យ៉ាងវិញទៀត តំណាងរាស្ត្រប្រហែល៩0%មានទីលំនៅ ឬស្នាក់នៅជាអចិន្ត្រៃយ៍នៅឯរាជធានីភ្នំពេញ

ពេលមានបញ្ហាកើតមានឡើង។ យោងតាមពតិមានបានបង្ហាញឱ្យដឹងថា មានតំណាងរាស្ត្រប្រមាណតែជាង ១០ រូបប៉ុណ្ណោះ ដែលបានស្នាក់នៅជាប់លាប់ក្នុងមណ្ឌលខេត្ត/ក្រុងរបស់ខ្លួន។

ជាឧទាហរណ៍ជាក់ស្តែង ក្នុងខែមីនា ២០០៤នេះ មានប្រជាពលរដ្ឋប្រមាណ១៦៦នាក់ មកពីស្រុកគូលែន ខេត្តព្រះវិហារ បានសុំឱ្យតំណាងរាស្ត្រជួយអន្តរាគមន៍ដោះស្រាយប្រាក់ពលីកងទ័ព។ ប៉ុន្តែគេពុំឃើញវត្តមានតំណាងរាស្ត្រទេ ព្រោះភាគច្រើនគាត់ឋិតនៅទីក្រុងភ្នំពេញ។

៣- <u>ការទំនាក់ទំនងរវាងតំណាងរាស្ត្រ និងរាជរដ្ឋាភិបាលបច្ចុប្បន្ន (រដ្ឋាភិបាលចាំផ្ទះ)</u>

បើយោងតាមស្មារតីរដ្ឋធម្មនុញ្ញ និងច្បាប់នានាដែលមានជាធរមាន នាពេលបច្ចុប្បន្ននេះ មិនមានការបញ្ជាក់ច្បាស់អំពីទំនាក់ទំនងរវាងសភាថ្មី និងរដ្ឋាភិបាលចាំផ្ទះ ដើម្បីរៀបចំថវិកាស្វយ័តរបស់សភា និងរយៈពេលនៃដំណើរការ "រដ្ឋាភិបាលចាំផ្ទះ" ទេ ដែលជាហេតុធ្វើឱ្យតំណាងរាស្ត្រជាប់ឆ្នោតថ្មី ពុំមានឥទ្ធិពលត្រួតពិនិត្យទៅលើស្ថាប័នរដ្ឋាភិបាលបច្ចុប្បន្ន។ ដូចនេះរដ្ឋាភិបាលបច្ចុប្បន្ន បានបដិសេធមិនច្បាស់លាស់ថា មិនផ្តល់ថវិកាស្វយ័តសំរាប់ប្រាក់បំណាច់ និងចំណាយលើដំណើរការការងារសភា ដោយគ្រាន់តែយកហេតុផលថា សភាគ្មានរចនាសម្ព័ន្ធនៅឡើយ។

៤- <u>ការធ្វើអន្តរាគមន៍ ការអំពាវនាវ/ស្នើវិធានការ និងការដាក់សំនួររបស់តំណាងរាស្ត្រ</u>

ការបញ្ចេញមតិយោបល់ ការអំពាវនាវ/ស្នើវិធានការ និងការដាក់សំនួររបស់តំណាងរាស្ត្រចំពោះបញ្ហាផ្សេងៗ ទៅស្ថាប័នពាក់ព័ន្ធ នានាពុំត្រូវបានយកចិត្តទុកដាក់ពីស្ថាប័នមានសមត្ថកិច្ច។ គិតចាប់តាំងពីខែធ្នូ ២០០៣ រហូតមកដល់ដំណាច់ខែមេសា ២០០៤ មានតែតំណាងរាស្ត្រគណបក្សសមរង្ស៊ីប៉ុណ្ណោះដែលបានធ្វើលិខិតយ៉ាងតិច៣០ច្បាប់ ផ្ញើទៅស្ថាប័ននានាក្នុងគោលបំណងស្នើសុំកិច្ចអន្តរាគមន៍សំណូមពរឬសំដែងនូវកង្វល់ផ្សេងៗទាក់ទងទៅបញ្ហារបស់ប្រជាពលរដ្ឋក្នុងមណ្ឌលរបស់ខ្លួន ក៏ដូចជាបញ្ហាជាតិទាំងមូល។ ស្ទើរតែទាំងអស់នៃសេចក្តីអំពាវនាវ និងការដាក់សំនួរទាំងនោះ គឺគ្មានចំលើយបកស្រាយផ្លូវការពីស្ថាប័នមានសមត្ថកិច្ច។ សេចក្តីអំពាវនាវ និងការដាក់សំនួរទាំងនោះមានដូចជា:

- សំណើសុំព្រះរាជទានទូវព្រះរាជអំណោយថ្លៃថ្លា ដើម្បីសង្គ្រោះប្រជារាស្ត្រជាកូនចៅចំនួន ៤៩៨គ្រួសាររស់នៅក្នុងឃុំស្អាងភ្នំ ស្រុកស្អាងខេត្តកណ្តាលដែលកំពុងខ្វះខាតស្បៀងធ្ងន់ធ្ងរ។ ពុំបានទទួលលិខិតឆ្លើយតបទេ ប៉ុន្តែឃើញមានក្រុមសម្តេចឪចុះជួយដោះស្រាយ។
- ការផ្តល់នូវអនុសាសន៍ ដើម្បីពិចារណាខាងគតិច្បាប់ជុំវិញបញ្ហា និងការស្នើសុំលុបចោលជាបន្ទាន់នូវការអនុញ្ញាតឱ្យបង្កើត និងបើកទីស្នាក់ការសាខាសមាគម វៀតណាមនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ (មិនទាន់ទទួលការឆ្លើយតប)

- សំណើសុំឱ្យបកស្រាយនូវសំនួរពាក់ព័ន្ធនឹងការអនុវត្តន៏ច្បាប់រដ្ឋធម្មនុញ្ញនិងច្បាប់ដទៃទៀត។ (សំណើនេះត្រូវបានបដិសេធម្តងហើយម្តងទៀតដោយក្រុមប្រឹក្សាធម្មនុញ្ញថាខុសនឹងទម្រង់ច្បាប់ ទោះបីយ៉ាងណាក៏ដោយ តំណាងរាស្ត្រគណបក្សសមរង្ស៊ីបន្តផ្ញើលិខិតទៅទៀត)។
- ការស្នើសុំចាត់វិធានការបញ្ឈប់សកម្មភាពអនាធិបតេយ្យ របស់ក្រុមជំរិតប្រាក់របស់ចំណតរថយន្តជ្រោយចង្វាជាបន្ទាន់...។ (មិនទាន់ទទួលការឆ្លើយតប)
- ស្នើសុំលុបចោល ចំណាត់ការចុះបង្ក្រាបដល់លំនៅដ្ឋានរបស់ អាជីវករ Internet Café។ សំណើនេះបានទទួលលិខិតឆ្លើយបំភ្លឺពី ឯកឧត្តមរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៏។
- ប្តឹងពីឯកឧត្តម សូ ឃុន រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៏ និងទូរគមនាគមន៏ និងនាយកក្រុមហ៊ុនទូរស័ព្ទម៉ូប៊ីថែល ពីបទស៊ីសំណូក និងបទសូកប៉ាន់។ (មិនទាន់ទទួលការឆ្លើយតប)
- ស្នើចាត់វិធានការបញ្ចុះតម្លៃ និងទប់ស្កាត់ ការប៉ុនប៉ងតម្លើងថ្លៃជាវអគ្គីសនីនៅខេត្តកំពង់ធំ។ ពុំទាន់មានការឆ្លើយតបនៅឡើយទេមកដល់ពេលនេះ។
- ស្នើចាត់វិធានការបញ្ឈប់ការលក់ព្រឲ្យសម្បត្តិសាធារណៈ ដោយមេឃុំកំពង់ក្រពៅ និងអាជ្ញាធរស្រុកស្ទឹងសែន។ ពុំទាន់មានការឆ្លើយតបនៅឡើយទេមកដល់ពេលនេះ
- សំណើសុំព្រះរាជានុញ្ញាតិឱ្យអធិការកិច្ចនៃក្រសួងយុត្តិធម៌ ធ្វើការស៊ើបអង្កេតក្នុងករណីដកតួនាទីនៃចៅក្រម និងព្រះរាជអាជ្ញាមួយចំនួន។ (មិនទាន់ទទួលការឆ្លើយតប)
- សំណើសុំចាត់វិធានការទប់ស្កាត់ និងបញ្ចុះតម្លៃប្រេងឥន្ធនៈ។ សំណើនេះត្រូវបានបដិសេធមិនធ្វើការឆ្លើយតបពីសំណាក់មន្ត្រីរដ្ឋាភិបាល ដោយបានចាត់ទុកថានោះជា*លិខិតធម្មតា និងជាមតិមួយ ព្រោះលិខិតនោះ ពុំបានធ្វើមកតាមប្រធានស្ថាប័ននីតិបញ្ញត្តិឡើយ*។
- សំណើរពិនិត្យករណីផ្ទាសំអុកគ្រូ មុី សុម៉ាឡា ពីជនបទមកបង្រៀននៅ សាលាក្នុងទីប្រជុំជនខេត្តសៀមរាបតាមគោលការណ៏ក្រសួងអប់រំ។ សំណើនេះ ត្រូវបានទទួលការឆ្លើយតបតាមរយៈលិខិតលេខ ៥៧៣ អយកខ.បលយ របស់មន្ទីរអប់រំខេត្ត ចុះថ្ងៃទី២៣ មេសា ២០០៤។
- សំណើចាត់វិធានការ និងការណែនាំដល់គ្រូពេទ្យ និងបុគ្គលិកពេទ្យ ឱ្យយកចិត្តទុកដាក់ជាអាទិភាពក្នុងការជួយសង្គ្រោះអាយុជីវិត ដល់អ្នកជំងឺ។ (មិនទាន់ទទួលការឆ្លើយតប)
- សុំចេញដីកាចាប់ខ្លួនមេដឹកនាំ "ក្រុមកម្ពុជាប្រជាធិបតេយ្យ" ហៅ "ខ្មែរក្រហម" ឈ្មោះ នួន ជា ឈ្មោះ អៀង សារី និង ឈ្មោះ ខៀន សំផន ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ រួមទាំងចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់មនុស្សធម៌អន្តរជាតិ

និងចំលាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាទទួលស្គាល់ ដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ១៧ មេសា ១៩៧៥ ដល់ថ្ងៃ ៦ មករា ១៩៧៩។ សំណើនេះបានទទួលលិខិតឆ្លើយតបលេខ៨៦/០៤ ភ្ជាប់ចុះកាលបរិច្ឆេទ ចុះហត្ថលេខាដោយលោក ហង់រ៉ូ រ៉ាកេន អគ្គព្រះរាជអាជ្ញានៃមហាអយ្យការសាលាឧទ្ធរណ៍។

- O សំណើសុំជួយដោះស្រាយការទាមទាររបស់បុគ្គលិកសណ្ឋាគារទាំង៦ ដែលកំពុងធ្វើកូដកម្មទាមទារលើប្រាក់កំរៃសេវា (បញ្ហានេះបាននិងកំពុងដោះស្រាយ)។
- O សំណើសុំចាត់វិធានការបិទបនល្បែងស៊ីសងយូគី នៅផ្សារប៉ាហ៊ី ក្រុងប៉ៃលិន។ មិនទាន់ទទួលការឆ្លើយតបនៅឡើយទេ រហូតមកដល់ពេលនេះ។ (សំណើនេះមិនបានទទួលការឆ្លើយតបទេ តែបនល្បែងបានបិទ ពីរ ឬបីថ្ងៃក្រោយពិធីចូលឆ្នាំខ្មែរ)។
- O អំពាវនាវដល់រាជរដ្ឋាភិបាលបង្កើតគណៈកម្មការឯករាជ្យមួយ ធ្វើការស៊ើបអង្កេតករណីមិនប្រក្រតីនៃប្រភពប្រាក់ចំណូលនេះ ដើម្បីបញ្ជាក់ថាប្រាក់នៅក្នុងភាគហ៊ុនលោកជំទាវ ទេព បុប្ផាប្រសិទ្ធ មិនពាក់ព័ន្ធនឹងអំពើពុករលួយ។ គ្មានការឆ្លើយតបជាផ្លូវការពីស្ថាប័នមានសមត្ថកិច្ច។
- O ទាមទារឱ្យរដ្ឋាភិបាលបច្ចុប្បន្ន បញ្ឈប់ជាបន្ទាន់នូវការលក់ទីតាំង សាលាស្រុកស្បែមរាបដោយខុសច្បាប់ គ្មានតម្លាភាព និងគ្មានការទទួលខុសត្រូវ។ (មិនទាន់ទទួលការឆ្លើយតប)
- O សំណើឱ្យអភិបាលក្រុងភ្នំពេញ រៀបចំគំរោងធ្វើស្ពានថ្មឆ្លងកាត់ផ្លូវថ្នល់ សំរាប់អ្នកថ្មើរជើងដើរឆ្លង។ សំណើនេះមិនបានទទួលលិខិតឆ្លើយតបជាផ្លូវការទេ។
- O សេចក្តីថ្លែងការណ៍សាធារណៈមួយ ព្រមានដល់អ្នកនិវិយោគដៃញ្ជែកសាង និងគ្រប់គ្រងទំនប់បូកគោ ថាជាដំណើរការខុសច្បាប់ និងមិនត្រូវបានទទួលស្គាល់ដោយរដ្ឋាភិបាលថ្មី។ ពុំទាន់មានប្រតិកម្មពីស្ថាប័នណាមួយនៅឡើយទេមកដល់ពេលនេះ។
- O សំណើចាត់វិធានការដាក់វិន័យរដ្ឋបាលដល់ ប្រធាននគរបាលប៉ុស្តិ៍រដ្ឋបាលពាមបាង ស្រុកស្ទោង ខេត្តកំពង់ធំ ដែលមិនបានចាត់វិធានការឃាត់ខ្លួនឈ្មោះ ដែលបានវាយមកលើជនរងគ្រោះ តាមរយៈការប្តឹងផ្តល់។ ពុំមានការឆ្លើយតបនៅឡើយទេមកដល់ពេលនេះ។
- O សំណើសុំចុះត្រួតពិនិត្យ និងមានវិធានការជាបន្ទាន់ ចំពោះការធ្វើអាជីវកម្មរ៉ែមាស នៅស្រុកសំបូរ ខេត្តក្រចេះ។ សំណើនេះមិនបានទទួលលិខិតឆ្លើយតបជាផ្លូវការទេ។
- O សេចក្តីថ្លែងការណ៍ពត៌មានសំដែងនូវការសោកស្តាយ ស្តីពី ការហាមឃាត់ការប្រារព្ធទិវាពលកម្មរបស់សហជីពកម្មករ និងគ្រូបង្រៀនចំនួនបួន ដែលបានស្នើសុំទៅអភិបាលក្រុង

ភ្នំពេញ កាលពីថ្ងៃទី ២៩ មេសា ២០០៤ ដើម្បីធ្វើការហែក្បួនតាមវិថីមួយចំនួនក្នុងទីក្រុង និងធ្វើមិទ្ទិញនៅបរិវេណសួនច្បារមុខវត្តបុទុមវត្តី។

(សូមមើលបន្ថែមនៅក្នុង **ឧបសម្ព័ន្ធ ៣** ចំនុចទី ៦)

៦. ដំណើរការចរចាបង្កើតរដ្ឋាភិបាលថ្មី

ការពិភាក្សារៀបចំរចនាសម្ព័ន្ធដឹកនាំរដ្ឋសភា បង្កើតរាជរដ្ឋាភិបាល និងការចងក្រងកម្មវិធីនយោបាយ និងពីធីសារសំរាប់កិច្ចសហប្រតិបត្តិការ:

- ដំណើរការពិភាក្សាមានតម្លាភាព និងពតិមានអាចទទួលបានច្រើនជាង ឆ្នាំ១៩៩៣ និង ១៩៩៨។
- មានភាពយឺតយ៉ាវ មានការផ្លាស់ប្តូរច្រើនដង ប៉ុន្តែមានការប្រុងប្រយ័ត្នខ្ពស់
- យកចិត្តទុកដាក់លើកម្មវិធីនយោបាយជាអាទិភាព ដែលគណបក្សនយោបាយនិមួយៗបានលើកឡើងក្នុងអំឡុងពេលឃោសនាបោះឆ្នោត ដូចជា:
  - ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ
  - ការកែទម្រង់ប្រព័ន្ធយុត្តិធម៌ ដើម្បីធានាឱ្យមានប្រព័ន្ធតុលាការស្អាតស្អំ
  - ការការពារនិងដោះស្រាយ បញ្ហាឯករាជ្យ អធិបតេយ្យភាព បូរណភាពទឹកដី
  - ជំរុញការអនុវត្តន៍ច្បាប់ស្តីពីសញ្ជាតិនិងច្បាប់ស្តីពីអន្តោប្រវេសន៍ឱ្យមាន ប្រសិទ្ធភាព
  - ការតម្លើងប្រាក់ប្រៀវត្សជូនមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ និងកម្មករ និយោជិត។
  - ការគ្រប់គ្រងប្រើប្រាស់ធនធានធម្មជាតិ រួមមាន ព្រៃឈើ ជលផលជាដើម
- កិច្ចពិភាក្សាក៏បានឆ្លើយតបទៅនឹងអនុសាសន៍របស់សង្គមស៊ីវិលផងដែរ ដូចជាទៅលើបញ្ហា:
  - ការបង្កើត និងជំរុញឱ្យមានដំណើរការស្ថាប័នឯករាជ្យថ្មី ដូចជាគណៈកម្មាធិការជាតិសិទ្ធិមនុស្ស គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គណកម្មាធិការប្រឆាំងអំពើពុករលួយជាដើម។
  - អនុម័តច្បាប់ថ្មីដែលជំរុញឱ្យមានតម្លាភាព និងការទទួលខុសត្រូវ រួមមានច្បាប់ប្រឆាំងអំពើពុករលួយជាដើម។
  - ពង្រឹងអំណាចនីតិបញ្ញត្តិ ដើម្បីត្រួតពិនិត្យការងាររបស់រដ្ឋាភិបាល
- មានកំលាំងថ្លឹងអំណាចនយោបាយប្រហាក់ប្រហែលគ្នាក្នុងការចរចា រវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សហ៊្វុនស៊ិនប៉ិច ព្រោះថាគណបក្សហ៊្វុនស៊ិនប៉ិចបានចងសម្ព័ន្ធភាពជាមួយគណបក្សសមរង្សុី បង្កើតជា "សម្ព័ន្ធភាពអ្នកប្រជាធិបតេយ្យ"។ យ៉ាងហោចណាស់ មានពតិមានពុំទាន់ផ្លូវការថា

គណបក្សហ៊ុនស៊ិនបុិចបានទទួលអាសនៈនៅក្នុងគណៈរដ្ឋមន្ត្រី ៤០% ឯគណបក្សប្រជាជនកម្ពុជា៦០% ហើយលទ្ធផលនៃការចរចាលើកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលសំរេចបាន៦០ចំនុចក្នុងចំណោម ៧៣ចុំនុច ។

- មានការជួបប្រជុំគ្នាមួយចំនួនរវាងគណបក្សជាប់ឆ្នោតទាំងបីដើម្បីពិភាក្សារៀបចំរដ្ឋសភា និងបង្កើតរាជរដ្ឋាភិបាលថ្មីត្រូវបានរៀបចំឡើង ។ ជំនួបទាំងនោះរួមមាន:

  ក. ជំនួបកំពូលនៃថ្នាក់ដឹកនាំគណបក្សជាប់ឆ្នោតទាំងបី ជាមួយព្រះមហាក្សត្រ ចំនួន ២លើក

  ១- កិច្ចប្រជុំក្រុមការងារបីគណបក្ស ក្រោមព្រះរាជាអធិបតីភាពព្រះមហាក្សត្រ ចំនួន ៣លើក

  ២- កិច្ចប្រជុំក្រុមការងារជាផ្លូវការបីគណបក្ស ចំនួន ២ លើក

  ខ. ជំនួបរវាងសម្តេចក្រុមព្រះនរោត្តមរណឫទ្ធិ ព្រះប្រធានគណបក្សហ៊ុនស៊ិនបុិច និងសម្តេចហ៊ុន សែន អនុប្រធានគណបក្សប្រជាជនកម្ពុជាថ្ងៃទី ១៥ មីនា ២០០៤ ។

  - កិច្ចប្រជុំក្រុមការងារជាផ្លូវការពីរគណបក្សមានចំនួន ៩លើក (គិតមកដល់ដំណាច់ខែមេសា ២០០៤) ។

  (សូមមើល **<u>ឧបសម្ព័ន្ធ ២</u>** សំរាប់ពត៌មានលំអិត)

ច. ស្ថានភាពគំរាមកំហែង បំភិតបំភ័យ និងឃាតកម្ម ពាក់ព័ន្ធសកម្មជននយោបាយ

មានពត៌មានស្តីពីករណីគម្រាមរកសម្លាប់ដល់តំណាងរាស្ត្រចំនួន ៥រូប គណបក្សហ៊ុនស៊ិនបុិច ពីររូប គណបក្សសមរង្ស៊ីបីរូប ដែលរួមមាន:

១- ស្តេចក្រុមឃុន នរោត្តម សិរីវុឌ្ឍ ព្រះអគ្គលេខាធិការគណបក្សហ៊ុនស៊ិនបុិច តំណាងរាស្ត្រមណ្ឌលកណ្តាល ។

២- ឯកឧត្តម សម រង្ស៊ី ប្រធានគណបក្សសមរង្ស៊ី តំណាងរាស្ត្រមណ្ឌលកំពង់ចាម

៣- ឯកឧត្តម អេង ឆៃអៀង អគ្គលេខាធិការគណបក្សសមរង្ស៊ី តំណាងរាស្ត្រមណ្ឌលបាត់ដំបង

៤- ឯកឧត្តម សុខ ផេង តំណាងរាស្ត្រមណ្ឌលកំពង់ធំ មកពីគណបក្សសមរង្ស៊ី ។

៥- ឯកឧត្តម លឺ ឡាយស្រេង ព្រឹទ្ធបុរសគណបក្សហ៊ុនស៊ិនបុិច តំណាងរាស្ត្រមណ្ឌលកណ្តាល ។

យោងតាមរបាយការណ៍ពីបណ្តាញខុមហ្រ្វែល និងសមាគមអាដហុកខេត្ត/ក្រុងទាំង២៤ និងអង្គការសិទ្ធិមនុស្សនានាក្នុងអំឡុងគិតចាប់តាំងពីខែតុលា ២០០៣ដល់ខែមេសា ២០០៤ មានករណីឃាតកម្មពាក់ព័ន្ធសកម្មជនគណបក្សនយោបាយចំនួន ១៧ករណី សំលាប់មនុស្សចំនួន ២០នាក់ ក្នុងនោះរួមមាន សកម្មជនគណបក្សសមរង្ស៊ី

ចំនួន១៣ នាក់ ស្លាប់សកម្មជនគណបក្សហ៊្វុនស៊ិនប៉ិចចំនួន ៣នាក់ ស្លាប់សកម្មជនគណបក្សប្រជាជនកម្ពុជាចំនួន ៤នាក់។ ក្នុងចំណោមករណីឃាតកម្មទាំងនេះ ភាគច្រើនបង្កឡើងដោយជនប្រដាប់អាវុធមិនស្គាល់ អត្តសញ្ញាណ។ ទន្ទឹមនឹងនេះ ក៏នៅមានករណីគំរាមកំហែងទៅលើសកម្មជនគណបក្សនយោបាយចំនួន ១៤ករណី ទៅលើសកម្មជនគណបក្សសមរង្ស៊ីចំនួន ៨ករណី ទៅលើសកម្មជនគណបក្សហ៊្វុនស៊ិនប៉ិចចំនួន ៦ករណី។ ករណីគំរាមកំហែងទាំងនេះច្រើនប្រព្រឹត្តឡើងដោយជនប្រដាប់អាវុធ និងអាជ្ញាធរមូលដ្ឋាន។ ហើយក្នុងករណីភាគច្រើន សមត្ថកិច្ចពុំដែលវែកមុខរកជនល្មើសប្រព្រឹត្តបទល្មើស ឬឃាតករឃើញទេ។ (សូមមើលបន្ថែម **<u>ឧបសម្ព័ន្ធ ៤</u>**)

ឆ. អនុសាសន៍:

ឆ្លងតាមរបាយការណ៍សង្កេតខាងលើនេះ **គណៈកម្មាធិការខុមហ្វ្រែល** សូមផ្តល់អនុសាសន៍ដូចតទៅនេះ

- *គួរពិនិត្យឡើងវិញនូវអនុសាសន៍របស់សង្គមស៊ីវិលចំនួន ៨ចំនុច ក្នុងសេចក្តីថ្លែងការណ៍រួម ចុះថ្ងៃទី ៣០ តុលា ២០០៣ ពិសេសការពង្រឹងសភា។*

ចំពោះរដ្ឋសភា

- *គួរពិនិត្យមើលក្របខ័ណ្ឌច្បាប់ឡើងវិញ អំពីរយៈពេលច្បាស់លាស់មួយក្នុងការបង្កើត "រដ្ឋាភិបាលថ្មី" និងការ វៀបចំរចនាសម្ព័ន្ធ និងដំណើរការសភាថ្មី។*
- *ក្នុងបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា គួរចែងអំពីភារកិច្ចរបស់តំណាងរាស្ត្រ ក្នុងការធ្វើទំនាក់ទំនងជាមួយ និងការទទួលខុសត្រូវចំពោះប្រជាពលរដ្ឋ ដោយឡែកចំពោះមណ្ឌលរបស់ខ្លួន និងការងារត្រួតពិនិត្យលើការងាររាជរដ្ឋាភិបាល ពិសេសការអនុវត្តន៍នៃកម្មវិធីនយោបាយឱ្យបានច្បាស់លាស់។*
- *គួរពង្រឹងសេវារបស់ការិយាល័យតំណាងរាស្ត្រ ដែលអាចផ្តល់លទ្ធភាពងាយដល់ប្រជាពលរដ្ឋ អាចជួបទំនាក់ទំនង។*

ចំពោះគណបក្សនយោបាយ

- *គួរមានគោលការណ៍ឱ្យច្បាស់អំពីការដកតំណាងរាស្ត្រ ឬការបាត់បង់សមាជិកភាពពីគណបក្សនយោបាយ។*
- *សមាជិកតំណាងរាស្ត្រម្នាក់ គួរត្រូវបានគណបក្សនយោបាយ លើកទឹកចិត្តក្នុងការទំនាក់ទំនងការងារផ្ទាល់ខ្លួន និងការបញ្ចេញទស្សនៈយោបល់ ឬរបាយការណ៍សកម្មភាពជាមួយអ្នកសង្កេតការណ៍។*

<u>ឧបសម្ព័ន្ធ ១:</u> ទិដ្ឋភាពស្ថាប័ន និងការលំបាកក្នុងការងារសង្កេតសកម្មភាពតំណាងរាស្ត្រ

១. សេចក្តីផ្តើមបញ្ហា

ការទទួលខុសត្រូវរបស់មន្ត្រីជាប់ឆ្នោត បង្ហាញឱ្យឃើញថាមានបញ្ហានៅក្នុងប្រព័ន្ធបោះឆ្នោត ចរិតនិងជំហរ និងសកម្មភាពទំនាក់ទំនងរវាងមន្ត្រីជាប់ឆ្នោត និងមណ្ឌលខេត្ត/ក្រុងរបស់ខ្លួន។ ក្នុងរបាយការណ៍នេះ មន្ត្រីជាប់ឆ្នោត គឺនិយាយដល់ តំណាងរាស្ត្រ។ ការទទួលខុសត្រូវរបស់តំណាងរាស្ត្រ គឺការបំពេញតួនាទី ភារកិច្ចនៅក្នុងរដ្ឋធម្មនុញ្ញ និងសកម្មភាពរបស់ខ្លួនជាតំណាង ឬទទួលខុសត្រូវចំពោះប្រជាពលរដ្ឋ រួមមានការចូលរួមអន្តរាគមន៍ដោះស្រាយបញ្ហាដែលទាក់ទិននឹងប្រជាពលរដ្ឋ។

១.១. ប្រព័ន្ធបោះឆ្នោតនៅកម្ពុជា

ប្រព័ន្ធបោះឆ្នោតនៃប្រទេសកម្ពុជា គឺជាប្រព័ន្ធបោះឆ្នោតសមាមាត្រ ដែលបេក្ខជនឈរឈ្មោះត្រូវតែជាសមាជិកគណបក្សនយោបាយ និងតែងតាំងដោយគណបក្សនយោបាយ។ ប្រព័ន្ធនេះពុំបានបង្កើនឱ្យមានការទទួលខុសត្រូវក្នុងការអនុវត្តន៍ការងារទេ ពីព្រោះសមាជិកជាប់ឆ្នោតទាំងនោះ (ឧទាហរណ៍ ដូចជាសមាជិករដ្ឋសភាជាដើម) ត្រូវបានគេបណ្តេញចេញពីតួនាទី នៅពេលដែលពួកគេហ៊ានបញ្ចេញមតិយោបល់ ដែលខុសពីមតិយោបល់របស់ថ្នាក់ដឹកនាំ រឺផលប្រយោជន៍គណបក្ស។ ប្រជាជនភាគច្រើនយល់ឃើញថា សមាជិកជាប់ឆ្នោត ទាំងនោះតំណាងឱ្យគណបក្សនយោបាយ ជាជាងតំណាងឱ្យប្រជាពលរដ្ឋ។ មានព្រឹទ្ធសមាជិក និងសមាជិករដ្ឋសភាមួយចំនួនហើយ ដែលត្រូវបានបណ្តេញចេញពីតួនាទីដោយសារតែមូលហេតុដូចខាងលើនេះ។ ប្រជាពលរដ្ឋមានការលំបាកក្នុងការធ្វើឱ្យមានឥទ្ធិពលដល់តំណាងជាប់ឆ្នោតទាំងនោះ ដើម្បីលើកឡើងនូវសំណើ និងសេចក្តីព្រួយបារម្ភទាំងឡាយរបស់ខ្លួន ទៅក្នុងកិច្ចពិភាក្សាតាមផ្លូវច្បាប់ និងការអនុម័តច្បាប់ថ្មីៗ។

១.២. កង្វះខាតក្នុងការទទួលខុសត្រូវរបស់មន្ត្រីជាប់ឆ្នោត

ចរិត និងជំហរ និងសកម្មភាពទំនាក់ទំនងរវាងជនកម្ពុជាធម្មតាជាមួយនឹងមន្ត្រីជាប់ឆ្នោត គឺមានកំរិត។ ការស្ទង់មតិនាឆ្នាំ២០០៣មួយ ស្តីពីអ្នកបោះឆ្នោតកម្ពុជាធ្វើឡើងដោយអង្គការមូលនិធិអាស៊ី បានបង្ហាញឱ្យឃើញថា ទោះបីជាប្រជាពលរដ្ឋកម្ពុជា ហាក់បីដូចជាយល់ស្របថា តំណាងរាស្ត្រជាប់ឆ្នោតយកចិត្តទុកដាក់ចំពោះពួកគេក៏ដោយ ក៏ប្រជាពលរដ្ឋកម្ពុជាប្រមាណ៦២% និយាយថា ពួកគេមិនបានចង់ចាំសូម្បីតែការចុះសួរសុខទុក្ខមួយរបស់តំណាងរាស្ត្រ និងប្រជាពលរដ្ឋកម្ពុជាប្រមាណ ៧៣% ពុំបានស្គាល់តំណាងរបស់ខ្លួនទេ។ សាធារណជនដឹងជាទូទៅនូវគោលការណ៍នៃគណនេយ្យភាព (ការទទួលខុសត្រូវ) របស់មន្ត្រីជាប់ឆ្នោត ទោះបីជាមានកំរិតតិចតួចនៅតំបន់ដាច់ស្រយាលក៏ដោយ។

២. គោលបំណង

បង្កើនតម្លាភាពក្នុងការអនុវត្តន៍តួនាទី ភារកិច្ចរបស់មន្ត្រីជាប់ឆ្នោត និងការបំពេញកិច្ចសន្យាក្នុងពេលបោះឆ្នោត។

ការឆ្លើយតបរបស់មន្ត្រីជាប់ឆ្នោត គឺជាសន្ទស្សន៍ចំបងមួយក្នុងចំណោមសន្ទស្សន៍នានា នៃជោគជ័យរបស់ដំណើរការប្រជាធិបតេយ្យ។ ការផ្តល់នូវតម្លាភាពក្នុងការអនុវត្តន៍ការងាររបស់មន្ត្រីជាប់ឆ្នោត នឹងត្រូវពឹងផ្អែកផងដែរ ទៅលើទំហំធំមួយ ស្តីពីប្រសិទ្ធភាពនៃការអង្កេត និងការចូលរួមពីប្រជាពលរដ្ឋថ្នាក់មូលដ្ឋាន។

យោងតាមបទពិសោធន៍កន្លងមករបស់ខុមប្រ៊ែល តួនាទីសង្កេតមិនមែនចាំបាច់តែក្នុងពេលបោះឆ្នោតប៉ុណ្ណោះទេ ប៉ុន្តែវាក៏ចាំបាច់សំរាប់ក្រោយពេលបោះឆ្នោត រហូតដល់ចប់អាណត្តិនៃមន្ត្រីជាប់ឆ្នោតផងដែរ។ ការអង្កេតប្រកបដោយចិរភាព នឹងជាឧបករណ៍ដ៏សំខាន់មួយ សំរាប់ផ្តល់ពត៌មានដល់មណ្ឌលខេត្ត/ក្រុង ព្រមទាំងធ្វើឱ្យប្រសើរឡើងនូវការបំពេញកិច្ចសន្យានានា និងទំនួលខុសត្រូវរបស់មន្ត្រីជាប់ឆ្នោត។

ខុមប្រ៊ែល នឹងរៀបចំរបាយការណ៍សង្កេតដោយអព្យាក្រឹត ព្រមទាំងការវាយតម្លៃនូវដំណើរការអនុវត្តន៍ការងាររបស់មន្ត្រីជាប់ឆ្នោត។ ខុមប្រ៊ែលបាននិងកំពុងពង្រាយអ្នកសង្កេតការណ៍របស់ខ្លួនចំនួនពីរក្រុម។ ក្រុមទី១ ដែលមានលេខាធិការខុមប្រ៊ែលទាំង២៤ខេត្ត/ក្រុង តាមឃ្លាំមើលសកម្មភាពចុះបេសកកម្មរបស់ សមាជិកសភាតំណាងរាស្ត្រ រួមមានចំនួនបេសកកម្ម និងការជួបប្រជុំជាមួយប្រជាពលរដ្ឋក្នុងមណ្ឌលរៀងៗខ្លួន។ ក្រុមទី២ គឺមានអ្នកសង្កេតការណ៍ខុមប្រ៊ែលពីរនាក់ (បុគ្គលិក និងអ្នកទំនាក់ទំនងនៅស្នាក់ការកណ្តាលភ្នំពេញ) តាមឃ្លាំមើលកិច្ចប្រជុំ ពិភាក្សារបស់រដ្ឋសភាជាតិ និងការសំដែងមតិយោបល់របស់មន្ត្រីជាប់ឆ្នោតចំពោះបញ្ហាមណ្ឌលខ្លួន និងបញ្ហាជាតិទាំងមូល។

៣. វិធីសាស្ត្រ

- លេខាធិការខុមប្រ៊ែលប្រចាំខេត្ត/ក្រុងទាំង២៤ ដែលបានទទួលការបណ្តុះបណ្តាល ត្រូវបានដាក់ពង្រាយដើម្បីសង្កេតលើសកម្មភាពរបស់តំណាងរាស្ត្រជាប់ឆ្នោតនៅក្នុងមណ្ឌលខេត្ត/ក្រុងរៀងៗខ្លួន។

- អ្នកសង្កេតការណ៍តម្រូវឱ្យចុះទំនាក់ទំនងសាកសួរពត៌មានជាមួយនឹងការិយាល័យ តំណាងរាស្ត្រទីស្នាក់ការ គណបក្សជាប់ឆ្នោតទាំងបីនៅតាមមណ្ឌល ខេត្ត/ក្រុងនីមួយៗ។

- អ្នកសង្កេតការណ៍តម្រូវឱ្យបំពេញទម្រង់អង្កេត (ដូចមានភ្ជាប់ជូនក្នុង **<u>ឧបសម្ព័ន្ធ ៦</u>**)

- តំណាងរាស្ត្រដែលត្រូវសង្កេតក្នុងពេលនេះ គឺជាបេក្ខជនតំណាងរាស្ត្រជាប់ឆ្នោតក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៣ ថ្ងៃទី២៧ កក្កដា ២០០៣ ដែលត្រូវបានប្រកាសទទួលស្គាល់ដោយ គ.ជ.ប នៅតាមមណ្ឌលខេត្ត/ក្រុងនិមួយ។ (សូមមើលតារាងបញ្ជីតំណាងរាស្ត្រ ភ្ជាប់ជូនក្នុង **<u>ឧបសម្ព័ន្ធ ៥</u>**)

- សកម្មភាពរបស់តំណាងរាស្ត្រជាប់ឆ្នោតដែលត្រូវសង្កេតរួមមាន ដំណើរចុះបេសកកម្មទៅកាន់មណ្ឌលរបស់ខ្លួននិងការជួបប្រជុំជាមួយប្រជាពលរដ្ឋ(គិតចាប់តាំងចំនួនដង គោលបំណង លទ្ធផលនៃបេសកកម្ម សំនូមពររបស់ប្រជាពលរដ្ឋមណ្ឌល និងការឆ្លើយតបរបស់តំណាងរាស្ត្រនីមួយៗ។

- របាយការណ៍ និងទិន្នន័យដែលប្រមូលបានពីបណ្តាញខេត្ត/ក្រុងខុមប្រៃ្រល នឹងត្រូវបានចងក្រងផ្សព្វផ្សាយជាសាធារណៈរៀងរាល់ឆមាស និងប្រចាំឆ្នាំ ដល់រដ្ឋសភា គណបក្សនយោបាយ សារពត៌មាន ជាពិសេសដល់ ប្រជាពលរដ្ឋនៅតាមមណ្ឌលខេត្ត/ក្រុងនីមួយៗ។

៤. ការលំបាកដែលជួបប្រទះ

ក្នុងការអនុវត្តន៏ការងារនេះ អ្នកសង្កេតការណ៍ខុមប្រៃ្រល បានជួបប្រទះនូវការលំបាកមួយចំនួនដូចជា: ពិបាកយកពត៌មាន ការិយាល័យតំណាងរាស្ត្រ និងស្នាក់ការគណបក្សនយោបាយ នៅតាមមណ្ឌលខេត្ត/ក្រុង ដែលភាគច្រើនពុំមានដំណើរការទេ គឺមានតែបុគ្គលិកម្នាក់ ឬពីរនាក់នៅប្រចាំការប៉ុណ្ណោះ។

ក្នុងចំណោមគណបក្សជាប់ឆ្នោតទាំងបី មានតែគណបក្សប្រជាជនកម្ពុជាមួយគត់ ដែលស្ទើរតែនៅគ្រប់មណ្ឌលខេត្ត/ក្រុង មិនសូវបានផ្តល់ពត៌មានអំពីតំណាងរាស្ត្រ នៅពេលដែលអ្នកសង្កេតការណ៍ខុមប្រៃ្រលសាកសួរដោយទាមទាររកលិខិតបញ្ជាបេសកកម្មពីស្ថាប័នសាមី ឬឆ្លើយថា: *មិនអាចនិយាយបានទេ!!!*

ដើម្បីសំរួលការងារដូចបានការទាមទារពីតំណាងរាស្ត្រខ្លះ ស្នាក់ការកណ្តាលខុមប្រៃ្រលធ្លាប់បានផ្ញើលិខិតមួយចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០០៤ ទៅគ្រប់គណបក្សដោយឡែក ខុទ្ទកាល័យគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា ជូនចំពោះឯកឧត្តម សាយ ឈុំ ជាអគ្គលេខាធិការគណបក្សសំណើសុំទំនាក់ទំនងពត៌មាន និងរបាយការណ៍ប្រចាំខែ ស្តីពីសកម្មភាពរបស់អ្នកតំណាងរាស្ត្រ ដែលចុះបេសកកម្មតាមមណ្ឌលខេត្ត/ក្រុងនានា។ ខុទ្ទកាល័យគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជាបានឆ្លើយ តបតាមរយៈលិខិតលេខ០០២ សជ.ខគក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០៤ ដែលមានខ្លឹមសារថា: *"តាំងពីនីតិកាល ទី១នៃរដ្ឋសភារហូតមកដល់បច្ចុប្បន្ននេះ ពុំដែលមានអង្គការជាតិ ឬអង្គការអន្តរជាតិណាមួយមកសុំការអនុញ្ញាតពី គណបក្សប្រជាជនកម្ពុជា ដើម្បីធ្វើការទំនាក់ទំនងជាមួយអ្នកតំណាងរាស្ត្ររបស់គណបក្សឡើយ ពីព្រោះនេះជា សមត្ថកិច្ចរបស់ប្រធានរដ្ឋសភាដូចមានចែងក្នុងរដ្ឋធម្មនុញ្ញនិងបទបញ្ជាផ្ទៃក្នុងរដ្ឋសភាស្រាប់។"* (សូមមើលលិខិតដែលមានភ្ជាប់ជូនក្នុង **<u>ឧបសម្ព័ន្ធ ៦</u>**)

ឧបសម្ព័ន្ធ ២: ការលប្បវត្តិ នៃដំណើរការចរចា

១. សង្ខេបសំខាន់ៗនៃដំណើរការចរចា គិតមកដល់ខែ មេសា ២០០៤

ក្រោយពីមានការរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៣ នាថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ២០០៣ គណបក្សនយោបាយចំនួនបី(៣) ត្រូវបានទទួលសំលេងគាំទ្រឱ្យទទួលបាននូវអាសនៈក្នុងរដ្ឋសភាជាតិ។ គណបក្សទាំងបីនោះរួមមាន គណបក្សប្រជាជនកម្ពុជាបានទទួល៧៣អាសនៈ គណបក្សហ៊្វុនស៊ិនប៉ិចបានទទួល២៦ អាសនៈ គណបក្សសមរង្ស៊ីបានទទួល២៤អាសនៈ (សរុប ១២៣ អាសនៈ)។

គណបក្សប្រជាជនកម្ពុជា បានទទួលអាសនៈចំនួនត្រឹមតែ ៧៣ ប៉ុណ្ណោះក្នុងចំណោមអាសនៈចំនួន១២៣ នៃរដ្ឋសភាជាតិ ដែលមិនអាចធ្វើឱ្យគណបក្សមានសំលេងគ្រប់គ្រាន់ (ពីរភាគបីនៃចំនួនសមាជិកសភាទាំងមូល) ដើម្បីរៀបចំរដ្ឋាភិបាលតែឯងបានទេ។ គណបក្សហ៊្វុនស៊ិនប៉ិច និងគណបក្សសមរង្ស៊ី បានអះអាងថា ពួកខ្លួននឹងមិនចូលរួមនៅក្នុងរដ្ឋាភិបាលចំរុះទេ ដរាបណាសម្តេច ហ៊ុន សែន នៅតែកាន់អំណាច។ គណបក្ស ទាំងពីរបានរួមគ្នាបង្កើតជា "**សម្ព័ន្ធភាពអ្នកប្រជាធិបតេយ្យ**" ហើយបានអះអាងថាប្រសិនបើចូលក្នុងរដ្ឋាភិបាល ចូលទាំងអស់គ្នា បើនៅក្រៅគឺនៅក្រៅទាំងអស់គ្នា។

ក្នុងកិច្ចប្រជុំកំពូលរវាងគណបក្សជាប់ឆ្នោតទាំងបី ជាមួយនឹងព្រះមហាក្សត្រនៅឯព្រះបរមរាជវាំង នាថ្ងៃទី ៥ វិច្ឆិកា ២០០៣ នោះ គណបក្សហ៊្វុនស៊ិនប៉ិច និងគណបក្សសមរង្ស៊ី បានយល់ព្រមទទួលនូវវរជនមួយរូបដែលស្នើឡើងដោយគណបក្សប្រជាជនកម្ពុជា ឱ្យធ្វើជានាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលនាអាណត្តិទី៣នេះ។ ហើយគណបក្សប្រជាជនកម្ពុជាឯកភាពទទួលយករដ្ឋាភិបាលត្រីភាគី។

បន្ទាប់ពីមិនបានទទួលលទ្ធផលជាវិជ្ជមាន ក្នុងការជួបប្រជុំពិភាក្សារបស់ក្រុមការងារគណបក្សទាំងបីចំនួនប្រាំលើករួចមក (ក្នុងនោះបីលើកក្រោមព្រះរាជាអធិបតីភាពព្រះមហាក្សត្រ-ដែលកិច្ចប្រជុំចុងក្រោយគឺនៅថ្ងៃទី ១៩ ធ្នូ ២០០៣-សូមមើលរបាយការណ៍លំអិតនៅទំព័របន្ទាប់) ភាពគាំងដំណើរបានអូសបន្លាយរហូតមកដល់ថ្ងៃទី ១៥ មីនា ២០០៤ ទើបមានការជួបគ្នារវាងសម្តេចក្រុមព្រះនរោត្តមរណឫទ្ធិ ព្រះប្រធានគណបក្សហ៊្វុនស៊ិនប៉ិច និងសម្តេច ហ៊ុន សែន អនុប្រធានគណបក្សប្រជាជនកម្ពុជា នៅឯដំណាក់វាលស្បូវ ដើម្បីពិភាក្សាស្វែងរកដំណោះស្រាយចំពោះភាពជាប់គាំងខាងនយោបាយបច្ចុប្បន្ន។

ជាលទ្ធផលភាគីទាំងពីរបានព្រមព្រៀងគ្នាបង្កើតក្រុមការងារ ដើម្បីពិភាក្សាគ្នាអំពីការរៀបចំរចនាសម្ព័ន្ធដឹកនាំរដ្ឋសភា និងរាជរដ្ឋាភិបាលថ្មី ព្រមទាំងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល។

សម្តេច ហ៊ុន សែន ក្នុងនាមគណបក្សប្រជាជនកម្ពុជា បានយល់ព្រមថ្វាយ សម្តេចក្រុមព្រះនរោត្តមរណឫទ្ធិ នូវលទ្ធភាពរើសបញ្ចូលនូវសមាជិក សមាជិកា ដែលមកពីគណបក្សផ្សេងក្រៅពីគណបក្សហ៊្វុនស៊ិនប៉ិច

ដាក់ទៅក្នុងសមាភាពរាជរដ្ឋាភិបាលអាណត្តិថ្មីនេះ។ មានការជួបប្រជុំរវាងក្រុមការងារនៃគណបក្សទាំងពីរមានចំនួន ៩លើកជាបន្តបន្ទាប់។

ក្នុងអំឡុងពេលនេះដែរ មានការប្តឹងផ្តល់គ្នារវាងមេដឹកនាំគណបក្សជាប់ឆ្នោតទាំងបី ចំនួន ៤ ករណីធំៗ ដូចជា:

- ថ្ងៃទី ៤ វិច្ឆិកា ២០០៣ សម្តេច ហ៊ុន សែន បានដាក់ពាក្យប្តឹងសម្តេចក្រុមព្រះនរោត្តមរណឬទ្ធិ ពីបទបរិហាកេរ្តិ៍ ជាប់ទាក់ទងទៅនឹងករណីឃាតកម្មទៅលើបុគ្គលិកវិទ្យុតារាព្រហ្ម កាលពីថ្ងៃទី ១៨ តុលា ២០០៣។

- ថ្ងៃទី ១ ធ្នូ ២០០៣ សម្តេចក្រុមព្រះនរោត្តមរណឬទ្ធិ បានដាក់ពាក្យប្តឹងតប សម្តេច ហ៊ុន សែន វិញ ពីបទញុះញង់បណ្តាលឱ្យមានអំពើឃាតកម្មទៅលើបុគ្គលិកវិទ្យុតារាព្រហ្មកាលពីថ្ងៃទី១៨ តុលា ២០០៣។

- ថ្ងៃទី ៣០ មករា ២០០៤ សម្តេច ហ៊ុន សែន បានដាក់ពាក្យប្តឹងឯកឧត្តម សម រង្ស៊ី ពីបទបរិហាកេរ្តិ៍ ជេរប្រមាថ និងញុះញង់ ដោយទាមទារជំងឺចិត្ត ៥ លានដុល្លាសហរដ្ឋអាមេរិក។

- ថ្ងៃទី ២ កុម្ភៈ ២០០៤ ឯកឧត្តម សម រង្ស៊ី បានដាក់ពាក្យប្តឹងតប សម្តេច ហ៊ុន សែន វិញ ពីបទសមគំនិតក្នុងអំពើមនុស្សឃាតគិតទុកជាមុន ដែលប្រព្រឹត្តទៅរាជធានីភ្នំពេញ កាលពីថ្ងៃទី ៣០ ខែមីនា ឆ្នាំ១៩៩៧ ដោយសុំទាមទារជំងឺចិត្តចំនួន ៥០ លានដុល្លាសហរដ្ឋអាមេរិក។

ចាប់តាំងពីក្រោយថ្ងៃប្រកាសលទ្ធផលបោះឆ្នោតផ្លូវការនាថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០៣ និងក្រោយថ្ងៃដែលសមាជិកសភាជាប់ឆ្នោតទាំងអស់ចូលធ្វើពិធីស្បថសច្ចាប្រណិធាននាថ្ងៃទី៤ ខែតុលា ឆ្នាំ២០០៣ រហូតមកដល់ដំណាច់ខែមេសា ២០០៤នេះ ដំណើរការចរចាដើម្បីបង្កើតរាជរដ្ឋាភិបាលថ្មី នៅមិនទាន់បានទទួលលទ្ធផលជាវិជ្ជមាននៅឡើយ។ ក្នុងអំឡុងពេលនេះ យើងសង្កេតឃើញថាមានការជួបប្រជុំគ្នាមួយចំនួនត្រូវបានរៀបចំឡើង។ ជំនួបទាំងនោះរួមមាន:

- ជំនួបកំពូលនៃថ្នាក់ដឹកនាំគណបក្សជាប់ឆ្នោតទាំងបី ជាមួយព្រះមហាក្សត្រ ចំនួន ២លើក
- កិច្ចប្រជុំក្រុមការងារបីគណបក្ស ក្រោមព្រះរាជាអធិបតីភាពព្រះមហាក្សត្រ ចំនួន ៣លើក
- កិច្ចប្រជុំក្រុមការងារជាផ្លូវការបីគណបក្ស ចំនួន ២ លើក
- ជំនួបរវាងសម្តេចក្រុមព្រះនរោត្តមរណឬទ្ធិ ព្រះប្រធានគណបក្សហ៊្វុនស៊ិនប៉ិច និងសម្តេច ហ៊ុន សែន អនុប្រធានគណបក្សប្រជាជនកម្ពុជាថ្ងៃទី ១៥ មីនា ២០០៤។

កិច្ចប្រជុំក្រុមការងារជាផ្លូវការពីរគណបក្ស ចំនួន ៩ លើក (គិតមកដល់ថ្ងៃទី៣០ មេសា ២០០៤)

២. ការលប្បវត្តិនៃដំណើរការចរចា

ជំនួបកំពូលនៃថ្នាក់ដឹកនាំគណបក្សជាប់ឆ្នោតទាំងបី ជាមួយព្រះមហាក្សត្រ

I - **នាថ្ងៃទី ៥ វិច្ឆិកា ២០០៣** កិច្ចប្រជុំកំពូលរវាងថ្នាក់ដឹកនាំគណបក្សនយោបាយជាប់ឆ្នោតទាំងបី បានប្រព្រឹត្តទៅនៅព្រះបរមរាជវាំង ក្រោមព្រះរាជាអធិបតីភាពព្រះមហាក្សត្រ។ ជំនួបនោះបានសម្រេចនូវខ្លឹមសារសំខាន់ៗ ដូចខាងក្រោមនេះ

១- បង្កើតរដ្ឋាភិបាលត្រីភាគី ដែលមានបេក្ខភាពនាយករដ្ឋមន្ត្រីស្នើឡើងដោយ គណបក្សប្រជាជនកម្ពុជា។

២- សម្តេចក្រុមព្រះនរោត្តមរណឫទ្ធិ ជាព្រះប្រធានរដ្ឋសភាជាតិព្រមទាំងបន្ថែមអនុប្រធានទី៣ នៃរដ្ឋសភាជាតិ(អនុប្រធានទី១និងទី២ មកពីគណបក្សប្រជាជនកម្ពុជា និងទី៣ មកពីគណបក្សសមរង្ស៊ី)។

៣- ឯកភាពបង្កើតក្រុមការងារចំនួនពីរ គឺក្រុមការងាររៀបចំរដ្ឋសភា និងក្រុមការងាររៀបចំរដ្ឋាភិបាល។

II - **ថ្ងៃទី ១១ វិច្ឆិកា ២០០៣** ព្រះមហាក្សត្របានកោះប្រជុំតំណាងគណបក្សនយោបាយទាំងបី ដើម្បីបញ្ជាក់ករណីដែលកាសែត ឌឺ ឃែមបូឌា ដេលី ចុះផ្សាយសំដីមន្ត្រីហ៊ុនសុិនបុិចដែលចោទប្រកាន់ព្រះអង្គថាបានបង្កិតបង្កំឱ្យគណបក្សហ៊ុនសុិនបុិច និងគណបក្សសមរង្ស៊ីឱ្យធ្វើតាមព្រះអង្គ។ ពេលនោះ ស្តេចក្រុមឃុននរោត្តមសិរីវុឌ្ឍ និងឯកឧត្តមសមរង្ស៊ី បានបដិសេធពតិមាននេះ ហើយបានអះអាងថា សេចក្តីថ្លែងការណ៍ថ្ងៃទី ៥ វិច្ឆិកា គឺជាការត្រឹមត្រូវ និងគ្មានការបង្កិតបង្កំ។

កិច្ចប្រជុំក្រុមការងារ ក្រោមព្រះរាជាអធិបតីភាពព្រះមហាក្សត្រ (៣លើក)

III - **ថ្ងៃទី ២៨ វិច្ឆិកា ២០០៣** ជំនួបរវាងតំណាងគណបក្សនយោបាយទាំងបី ក្រោមព្រះរាជាអធិបតីភាពព្រះមហាក្សត្រ (យោងតាមការកោះអញ្ជើញពីព្រះមហាក្សត្រចុះថ្ងៃទី ២៧ វិច្ឆិកា ២០០៣) បានឯកភាពកំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំក្រុមការងារបីគណបក្ស គឺថ្ងៃទី ៤ ធ្នូ ២០០៣ ប្រជុំការងាររដ្ឋសភា និងថ្ងៃទី ៦ ធ្នូ ២០០៣ ប្រជុំការងាររដ្ឋាភិបាល។

IV - **ថ្ងៃទី ៤ ធ្នូ ២០០៣** ក្រុមការងាររដ្ឋសភាបីគណបក្សបានជួបប្រជុំគ្នានៅក្នុងព្រះបរមរាជវាំងក្រោមព្រះរាជាអធិបតីភាពព្រះមហាក្សត្រ។ ក្រុមសម្ព័ន្ធភាពស្នើកោះប្រជុំសភា ក្រោមអធិបតីភាពព្រឹទ្ធបុរសសមាជិកសភា ជា សុទ្ធ។ គណបក្សប្រជាជនកម្ពុជាសុំយកសំណើនេះ ទៅឆ្លងថ្នាក់ដឹកនាំគណបក្សសិនទើបឆ្លើយតប។

V - <u>ថ្ងៃទី ៦ ធ្នូ ២០០៣</u> ក្រុមការងាររាជរដ្ឋាភិបាលបីគណបក្សបានជួបប្រជុំគ្នានៅក្នុងព្រះបរមរាជវាំង ក្រោមព្រះរាជាអធិបតីភាពព្រះមហាក្សត្រ។ កិច្ចប្រជុំបានអូសបន្លាយអស់រយៈពេលប្រាំពីរម៉ោង ដែលគ្រោងថាជាកិច្ចប្រជុំការងារដើម្បីបង្កើតរាជរដ្ឋាភិបាលថ្មី បានក្លាយជាវេទិកាចោទគ្នាទៅវិញទៅមក រវាងគណបក្សប្រជាជនកម្ពុជា និងក្រុមសម្ព័ន្ធភាពអ្នកប្រជាធិបតេយ្យ របស់គណបក្សហ៊្វុនស៊ិនប៉ិច និងគណបក្សសមរង្ស៊ី។ ជាលទ្ធផលគឺគណបក្សទាំងបី បានឯកភាពគ្នាកំណត់យកថ្ងៃ ១៥ - ១៦ ឬ ១៧ ធ្នូ សម្រាប់ឱ្យរដ្ឋសភាថ្មី បើកការប្រជុំ។

កិច្ចប្រជុំក្រុមការងាររដ្ឋាភិបាលបីគណបក្ស (មានចំនួន ២ លើក)

VI - <u>ថ្ងៃទី ១៧ ធ្នូ ២០០៣</u> ក្រុមការងាររដ្ឋសភាបីគណបក្សបានជួបប្រជុំគ្នានៅក្នុងព្រះបរមរាជវាំង។ កិច្ចប្រជុំបានអូសបន្លាយអស់រយៈពេលប្រាំមួយម៉ោង។ គណបក្សទាំងបី បានដាក់ស្នើរបៀបវារៈ គឺការរៀបចំឱ្យមានសេចក្តីស្នើច្បាប់រដ្ឋធម្មនុញ្ញបន្ថែម ស្តីពីការបោះឆ្នោតជាកញ្ចប់ជ្រើសតាំងរចនាសម្ព័ន្ធដឹកនាំរដ្ឋសភា និងផ្តល់សេចក្តីទុកចិត្តដល់រាជរដ្ឋាភិបាលនៅដើមនីតិកាលនីមួយៗ និងរៀបចំបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ។

ចំណែកគណបក្សហ៊្វុនស៊ិនប៉ិចបានដាក់ស្នើ ៦ របៀបវារៈ គឺធ្វើការអនុម័តលើបទបញ្ជាផ្ទៃក្នុង ការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ កាលបរិច្ឆេទធ្វើច្បាប់ដែលបានចែងក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ វិធានការធ្វើវិសោធនកម្មច្បាប់មួយចំនួនស្នើលុបចោលកិច្ចព្រមព្រៀង និងសន្ធិសញ្ញាមួយចំនួនជាមួយបរទេសពាក់ព័ន្ធនិងអធិបតេយ្យជាតិ បូរណភាពដែនដី មុខនាទី និងការទទួលខុសត្រូវលើការដឹកនាំរដ្ឋសភា។

ដោយឡែកគណបក្សសមរង្ស៊ីបានស្នើ៤របៀបវារៈ គឺ**ការរៀបចំបទបញ្ជាផ្ទៃក្នុងថ្មី វិសោធនកម្មរដ្ឋធម្មនុញ្ញ វិធានការកែទម្រង់ស្ថាប័ន និងច្បាប់មួយចំនួនដែលរដ្ឋសភាត្រូវធ្វើមុនការបង្កើតរដ្ឋា ភិបាលថ្មី** ដូចជាការអនុម័តលុបចោលសន្ធិសញ្ញាព្រំដែនជាតិ។ កិច្ចប្រជុំក្រុមការងាររដ្ឋសភាទាំងបីគណបក្សបានសម្រេចប្រជុំម្តងទៀតនៅថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ២០០៣ ។

VII - <u>ថ្ងៃទី ១៩ ធ្នូ ២០០៣</u> ក្រុមការងាររដ្ឋសភាទាំងបីគណបក្ស បានជួបប្រជុំម្តងទៀតនៅព្រះរាជដំណាក់គន្ធបុប្ផាអស់រយៈពេល៣ម៉ោង ដោយពុំទទួលបានលទ្ធផលអ្វីឡើយ ក្នុងនោះបានពិចារណាអំពីលទ្ធភាពនៃការប្រជុំថ្នាក់ដឹកនាំទាំងបីគណបក្ស អំពីបញ្ហារបៀបវារៈដែលស្នើឡើងដោយគណបក្សទាំងបី។

ជំនួបលើកទីមួយ រវាងសម្តេចក្រុមព្រះនរោត្តមរណឫទ្ធិ ព្រះប្រធានគណបក្សហ៊្វុនស៊ិនប៉ិច និងសម្តេច ហ៊ុន សែន អនុប្រធានគណបក្សប្រជាជនកម្ពុជា នាថ្ងៃទី ១៥ មីនា ២០០៤ នៅដំណាក់វាលស្បូវ ស្រុកក្បៀនស្វាយ ខេត្តកណ្តាល

VIII - <u>ថ្ងៃទី ១៥ មីនា ២០០៤</u> វេលាម៉ោង ១៧ រសៀល សម្តេចក្រុមព្រះនរោត្តមរណឫទ្ធិ ព្រះប្រធានគណបក្សហ៊្វុនស៊ិនប៉ិច និងសម្តេច ហ៊ុន សែន អនុប្រធានគណបក្សប្រជាជនកម្ពុជា បានជួបគ្នារយៈពេលជិតពីរម៉ោងនៅឯដំណាក់វាលស្បូវ ស្រុកក្បៀនស្វាយ ខេត្តកណ្តាល ដើម្បីពិភាក្សាស្វែងរកដំណោះស្រាយចំពោះភាពជាប់គាំងខាងនយោបាយបច្ចុប្បន្ន។

ជាលទ្ធផលភាគីទាំងពីរបានព្រមព្រៀងគ្នាបង្កើតក្រុមការងារ ដើម្បីពិភាក្សាគ្នាអំពីការរៀបចំរចនាសម្ព័ន្ធដឹកនាំរដ្ឋសភា និងរាជរដ្ឋាភិបាលថ្មី ព្រមទាំងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល។

ស្តីអំពីសមាសភាពនៃរាជរដ្ឋាភិបាលអាណត្តិថ្មីនេះ សម្តេច ហ៊ុន សែន ក្នុងនាមគណបក្សប្រជាជនកម្ពុជា បានយល់ព្រមថ្វាយសម្តេចក្រុមព្រះនរោត្តមរណឫទ្ធិ នូវលទ្ធភាពរើសបញ្ចូលនូវសមាជិកសមាជិកា ដែលមកពីគណបក្សផ្សេងក្រៅពីគណបក្សហ៊្វុនស៊ិនប៉ិច។

កិច្ចប្រជុំក្រុមការងារជាផ្លូវការពីរគណបក្ស (មានចំនួន ៩ លើក)

IX - <u>ថ្ងៃទី ២៨ មីនា ២០០៤</u> បន្ទាប់ពីមានជំនួបរវាង សម្តេចក្រុមព្រះនរោត្តមរណឫទ្ធិ ព្រះប្រធានគណបក្សហ៊្វុនស៊ិនប៉ិច និងសម្តេច ហ៊ុន សែន អនុប្រធានគណបក្សប្រជាជនកម្ពុជា ឯដំណាក់វាលស្បូវរួចមក ក្រុមការងារគណបក្សទាំងពីរ បានជួបប្រជុំគ្នានៅទីស្នាក់ការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាលើរបៀបវារៈបី:

- ពិភាក្សាអំពីកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលចំរុះ
- ពិភាក្សាលើពិធីសារនៃកិច្ចព្រមព្រៀងសហប្រត្តិបត្តិការ រវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សហ៊្វុនស៊ិនប៉ិច
- ពិភាក្សាអំពីរចនាសម្ព័ន្ធដឹកនាំរដ្ឋសភា និងរាជរដ្ឋាភិបាលថ្មី

នៅក្នុងកិច្ចប្រជុំនោះ ក្រុមការងារគណបក្សទាំងពីរបានស្តាប់ការធ្វើអត្ថាធិប្បាយសង្ខេបដោយតំណាងក្រុមការងារនីមួយៗ អំពីសេចក្តីព្រាងកម្មវិធីនយោបាយនេះ ដោយបានធ្វើការវាយតម្លៃថាកម្មវិធីនយោបាយនេះមានចំនុចរួមប្រហាក់ប្រហែលគ្នាច្រើននៅក្នុងសេចក្តីព្រាងទាំងពីរ។

ជាលទ្ធផល ក្រុមការងារគណបក្សទាំងពីរបានផ្លាស់ប្តូរគ្នាទៅវិញទៅមក នូវសេចក្តីព្រាងកម្មវិធីនយោបាយសំរាប់រាជរដ្ឋាភិបាលចំរុះ ដែលបានស្នើឡើងដោយគណបក្សរៀងៗខ្លួន ដើម្បីយកទៅធ្វើការសិក្សាបន្ថែម និងកំណត់កាលបរិច្ឆេទជួបគ្នាជាថ្មីនៅថ្ងៃទី ១ មេសា ២០០៤។

X - **<u>ថ្ងៃទី ១ មេសា ២០០៤</u>** ចាប់ពីម៉ោង ៩ ព្រឹក រហូតដល់ម៉ោង ១២ ថ្ងៃត្រង់ ក្រុមការងារ គណបក្សទាំងពីរ គឺគណបក្សប្រជាជនកម្ពុជា និងគណបក្សហ៊្វុនស៊ិនប៉ិច បានជួបគ្នាជាថ្មីម្តងទៀតតាមការគ្រោងទុកនៅឯទីស្នាក់ការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាដដែល។

ក្នុងកិច្ចប្រជុំនោះ គឺរបៀបវារៈទីមួយ ត្រូវបានលើកយកពិភាក្សា គឺទាក់ទងទៅនឹងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលចំរុះ ដែលរួមមាន៧៣ចំនុច។ ជាលទ្ធផល គណបក្សទាំងពីរបានឯកភាពគ្នាលើចំនុចចំនួនប្រាំមួយក្នុងចំណោម១១ចំនុចដែលបានពិភាក្សា។ ចំណែកឯចំនុចចំនួនប្រាំទៀត ដែលមិនទាន់បានឯកភាពគ្នានោះ ក្រុមការងារគណបក្សទាំងពីរនឹងយកទៅពិភាក្សាផ្ទៃក្នុងគណបក្សរៀងៗខ្លួន ហើយនឹងយកមកពិភាក្សាក្នុងកិច្ចប្រជុំនាថ្ងៃទី ២ មេសា ជាបន្តទៀត។ ចំនុចទាំងនោះរួមមាន:

- ~ ការបង្កើតស្ថាប័នឯករាជ្យ អព្យាក្រឹត្យ "គណៈកម្មាធិការជាតិសិទ្ធិមនុស្ស"
- ~ ការតម្រូវឱ្យនាយករដ្ឋមន្ត្រី និងសមាជិករាជរដ្ឋាភិបាលបង្ហាញខ្លួនចំពោះមុខរដ្ឋសភា ដើម្បីឱ្យតំណាងរាស្ត្រសាកសួរ ក្នុងមួយខែម្តងដោយគ្មានរបៀបវារៈ។ ធ្វើវេទិការាស្ត្រ និងរដ្ឋក្នុងបីខែម្តងឱ្យប្រជាពលរដ្ឋមកសាកសួរនាយករដ្ឋមន្ត្រី គណៈរដ្ឋមន្ត្រី អំពីបញ្ហាផ្សេងៗ។
- ~ សេរីភាពខាងសារពត៌មាន និងការបញ្ចេញមតិ...ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃសមាជជាតិត្រូវអនុម័តឱ្យបានមុនដំណាច់ឆ្នាំ២០០៤។
- ~ បង្កើតច្បាប់ស្តីពីដំណើរការគណបក្សប្រឆាំង
- ~ បង្កើតច្បាប់ស្តីពីអង្គការមិនមែនរដ្ឋាភិបាល និងសមាគម

XI - **<u>ថ្ងៃទី ២ មេសា ២០០៤</u>** ចាប់ពីម៉ោង៣ រសៀល ក្រុមការងារគណបក្សទាំងពីរ គឺគណបក្សប្រជាជនកម្ពុជា និងគណបក្សហ៊្វុនស៊ិនប៉ិច បានជួបគ្នាជាលើកទីបីតាមការគ្រោងទុកនៅកន្លែងដដែល។

ក្នុងកិច្ចប្រជុំនោះ គឺរបៀបវារៈទីមួយដដែល ត្រូវបានលើកយកពិភាក្សាបន្តទៀតទៅលើ៤ចំនុច រួមមាន: អភិបាលកិច្ចល្អ និងកំណែទម្រង់រដ្ឋបាលសាធារណៈ។ ចំណែកឯចំនុចទាំងប្រាំដែលពុំទាន់បានឯកភាពគ្នា ត្រូវបានក្រុមការងារគណបក្សទាំងពីរ សន្យាថានឹងលើកយកទៅពិភាក្សាទៅថ្ងៃទី ៦ មេសា ២០០៣។

ជាលទ្ធផលគណបក្សទាំងពីរបានឯកភាពច្រើនលើចំនុចដែលបានពិភាក្សាថ្ងៃនេះ ប៉ុន្តែគណបក្សប្រជាជនកម្ពុជាពុំទាន់បានឯកភាពនៅឡើយទេ លើចំនុច<u>តម្លើងប្រៃវិត្សជូនមន្ត្រីរាជការជាជំហានៗឱ្យបាន ១០០ដុល្លាអាមេរិក មុនដំណាច់ឆ្នាំ២០០៧</u>។

យោងតាមកិច្ចសម្ភាសន៍រវាងឯកឧត្តម ប្រាក់ សុខុន អ្នកនាំពាក្យក្រុមការងារគណបក្សប្រជាជនកម្ពុជាជាមួយនឹងអ្នកយកពត៌មានបន្ទាប់ពីចប់កិច្ចប្រជុំនារសៀលថ្ងៃនោះ ទាក់ទងទៅនឹងចំនុចទាំងប្រាំដែលមិនទាន់បានយកមកពិភាក្សាគ្នានោះថា:

- ~ ទាក់ទងទៅនឹងការបង្កើត "គណៈកម្មាធិការជាតិសិទ្ធិមនុស្ស" គណបក្សប្រជាជនកម្ពុជាបានឯកភាពឱ្យបង្កើត ដោយរក្សាទុកគណៈកម្មាធិការសិទ្ធិមនុស្សរបស់រាជរដ្ឋាភិបាលដែលមានស្រាប់ ។
- ~ ការតម្រូវឱ្យនាយករដ្ឋមន្ត្រី និងសមាជិករាជរដ្ឋាភិបាលបង្ហាញខ្លួនចំពោះមុខរដ្ឋសភាដើម្បីឱ្យតំណាងរាស្ត្រសាកសួរ ក្នុងមួយខែម្តងដោយគ្មានរបៀបវារៈ។ ធ្វើវេទិការាស្ត្រនិងរដ្ឋក្នុងបីខែម្តងឱ្យប្រជាពលរដ្ឋមកសាកសួរនាយករដ្ឋមន្ត្រី គណៈរដ្ឋមន្ត្រី អំពីបញ្ហាផ្សេងៗ។ ចំនុចនេះត្រូវបានគណបក្សប្រជាជនកម្ពុជា កែសម្រួលថា: នាយករដ្ឋមន្ត្រី និងសមាជិករាជរដ្ឋាភិបាលត្រៀមខ្លួនដើម្បីឆ្លើយឆ្លងជាមួយតំណាងរាស្ត្រ នៃរដ្ឋសភាស្របតាមស្មារតីមាត្រា ៥៦ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។
- ~ សេរីភាពខាងសារពត៌មាន និងការបញ្ចេញមតិ...ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃសមាជជាតិត្រូវអនុម័តឱ្យបានមុនដំណាច់ឆ្នាំ២០០៤។ គណបក្សប្រជាជនកម្ពុជា កែសម្រួលថា: ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃសមាជជាតិត្រូវអនុម័ត ឱ្យបានឆាប់ដែលអាចធ្វើទៅបាន។
- ~ ពាក់ព័ន្ធនឹងការបង្កើតច្បាប់ស្តីពីដំណើរការគណបក្សប្រឆាំង គណបក្សប្រជាជនកម្ពុជាបានបញ្ជាក់ថា កម្ពុជាមានច្បាប់ស្តីពីគណបក្សនយោបាយហើយកន្លងមក ដូច្នេះគួរធ្វើត្រឹមវិសោធនកម្មដោយបញ្ចូលបញ្ញត្តិមួយស្តីពីគណបក្សប្រឆាំង។
- ~ បង្កើតច្បាប់ស្តីពី (ការវិភាគទានចំពោះ) អង្គការមិនមែនរដ្ឋាភិបាលនិងសមាគម។ ចំនុចនេះមានក្នុងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលអាណត្តិទីពីររួចមកហើយ នេះគ្រាន់តែជាការរក្សានិរន្តរភាពនូវអ្វីដែលបានធ្វើ។

ក្រុមការងារគណបក្សទាំងពីរបានព្រមព្រៀងគ្នាប្តូរយុទ្ធសាស្ត្រដើម្បីពន្លឿនការពិភាក្សា ដោយធ្វើការប្តូរពីការពិភាក្សាលើមួយចំនុចម្តងៗ មកសិក្សាលើចំនុចទាំងអស់ ហើយលើកយកតែចំនុចដែលមិនត្រូវគ្នាមកពិភាក្សាប៉ុណ្ណោះ។

XII - រសៀល <u>ថ្ងៃទី ៨ មេសា ២០០៤</u> ក្រុមការងារគណបក្សទាំងពីរ គឺគណបក្សប្រជាជនកម្ពុជានិងគណបក្សហ៊្វុនស៊ិនប៉ិច បានជួបគ្នាជាលើកទីបួននៅកន្លែងដដែល (តាមការគ្រោងទុកកិច្ចប្រជុំលើកនេះត្រូវធ្វើនៅថ្ងៃទី ៦ មេសា ២០០៤ ប៉ុន្តែត្រូវបានលើកពេលមូលហេតុដោយសារ **ឯកឧត្តម តុល ឆ្លោះ**

អតីតឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងជាសមាជិកគណកម្មាធិការនាយកនៃគណបក្សហ៊្វុនស៊ិនបិចបានទទួលមរណភាព) ។

ក្នុងកិច្ចប្រជុំលើកទីបួននោះ ពុំទទួលបានលទ្ធផលអ្វីជាដុំកំភួនទេ ដោយគណបក្សប្រជាជនកម្ពុជាយកវេទិកានេះ ដើម្បីពន្យល់ឆ្លើយតបទៅនឹងសំណើរបស់គណបក្សហ៊្វុនស៊ិនបិចក្នុងកិច្ចប្រជុំមុនៗ ដែលត្រូវបានមន្ត្រីនៃក្រុមការងារគណបក្សហ៊្វុនស៊ិនបិច និយាយថាគណបក្សប្រជាជនកម្ពុជា ហាក់ដូចជាពុំទាន់បង្ហាញឆន្ទៈពិតប្រាកដនៅឡើយទេទាក់ទងទៅនឹងសំណើទាំងនោះ ។

XIII - <u>ថ្ងៃទី ៩ មេសា ២០០៤</u> ចាប់ពីម៉ោង ៣ រសៀល ក្រុមការងារគណបក្សនយោបាយទាំងពីរបានជួបគ្នាជាលើកទីប្រាំតាមការគ្រោងទុកនៅកន្លែងដដែល ដើម្បីបន្តពិភាក្សាលើរបៀបវារៈទីមួយស្តីពីកម្មវិធីនយោបាយ។ យោងតាមអ្នកនាំពាក្យនៃគណបក្សទាំងពីរ បានអះអាងថា កិច្ចប្រជុំថ្ងៃនេះមានការរីកចំរើនទៅមុខច្រើន បើប្រៀបធៀបនឹងកិច្ចប្រជុំលើកមុនៗ ដោយគណបក្សនយោបាយទាំងពីរព្រមព្រៀងគ្នាបង្កើតក្រសួងអន្តោប្រវេសន៍ និងក្រសួងការងារ ដោយបំបែកចេញពីក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទាបច្ចុប្បន្ន ហើយក្រុមការងារបានពិភាក្សា និងឯកភាពគ្នាលើចំនុចចំនួន៣៣ ក្នុងចំណោម៧៣ចំនុច ។

ចំណែកឯចំនុចប្រាំដែលទាក់ទងនឹងការពង្រឹងលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ព្រមទាំងការតម្លើងប្រាក់បៀវត្សជូនមន្ត្រីរាជការ នៅពុំទាន់ឯកភាពគ្នានៅឡើយទេ ហើយថានឹងលើកយកទៅពិភាក្សានៅក្រោយពិធីចូលឆ្នាំខ្មែរថ្ងៃទី១៦ មេសា ២០០៤ ។ ចំនុចទាំងឡាយដែលពិបាកនឹងត្រូវគ្នាក្នុងកិច្ចប្រជុំក្រុមការងារ អាចនឹងដាក់ជូនមេដឹកនាំគណបក្សនយោបាយទាំងពីរសំរេច ។

XIV - <u>ថ្ងៃទី ១៦ មេសា ២០០៤</u> ចាប់ពីម៉ោង ៩ ព្រឹក ក្រុមការងារគណបក្សទាំងពីរបានជួបគ្នាជាលើកទីប្រាំមួយតាមការគ្រោងទុកនៅកន្លែងដដែល ។ ជាលទ្ធផល ក្រុមការងារនៃគណបក្សទាំងពីរបានចុះហត្ថលេខាព្រមព្រៀងគ្នាលើចំនុចចំនួន ៥០ ក្នុងចំណោម ៧៣ចំនុច ។ ចំនុចដែលនៅសល់នឹងត្រូវលើកយកទៅពិភាក្សាគ្នានៅថ្ងៃទី ២៨ មេសា ២០០៤ ។ កាលពីថ្ងៃទី១៥ មេសា ២០០៤ គណបក្សហ៊្វុនស៊ិនបិច និងគណបក្សសមរង្ស៊ី ក្នុងនាមសម្ព័ន្ធភាពអ្នកប្រជាធិបតេយ្យបានចេញសេចក្តីថ្លែងការណ៍មួយស្តីពីចំណុចចំនួន២១ ក្នុងចំណោម ៧៣ចំនុច ដែលក្រុមការងារគណបក្សប្រជាជនកម្ពុជា និងគណបក្សហ៊្វុនស៊ិនបិចមិនទាន់បានព្រមព្រៀងនៅឡើយទេ នៅក្នុងដំណើរការពិភាក្សាប្រាំលើកកន្លងមកនេះ ។

ចំណុចទាំង ២១ នោះរួមមាន:

១- ការបង្កើត "គណៈកម្មាធិការជាតិសិទ្ធិមនុស្ស" ជំនួសគណៈកម្មការសិទ្ធិមនុស្សរបស់រាជរដ្ឋាភិបាល

២- នាយករដ្ឋមន្ត្រី និងសមាជិករាជរដ្ឋាភិបាលអញ្ជើញទៅឆ្លើយដោយផ្ទាល់មាត់នៅចំពោះមុខរដ្ឋសភាមួយខែម្តង។

៣- វេទិការាស្ត្រ និងមន្ត្រី បីខែម្តង។

៤- បញ្ហាពាក់ព័ន្ធជាមួយប្រាក់ជំនួយដល់អង្គការមិនមែនរដ្ឋាភិបាល

៥- ការតម្លើងប្រាក់ប្សៀវត្សឱ្យបាន ១00 ដុល្លាយ៉ាងតិចជូនមន្ត្រីរាជការ រួមទាំងទាហាន ប៉ូលីស។

៦- ការលុបចោលកិច្ចព្រមព្រៀងព្រំដែនខុសច្បាប់ជាមួយប្រទេសជិតខាង។

៧- ការបញ្ចុះតម្លៃប្រេងឥន្ធនៈឱ្យនៅប្រហាក់ប្រហែលនឹងប្រទេសជិតខាង (១៤00 រៀលក្នុងមួយលីត្រ)។

៨- ការផ្ទៀងផ្ទាត់គណៈកម្មការទទួលស្គាល់គុណភាពអប់រំពី ទីស្តីការគណៈរដ្ឋមន្ត្រីមកក្រសួងអប់រំ។

៩- ការតម្លើងប្រាក់ខែរួមទាំងប្រាក់កម្រៃសន្តិសុខសង្គម ឱ្យបាន៧0ដុល្លាក្នុងមួយខែជូនកម្មករសំណង់។

១0- ការកែទម្រង់រចនាសម្ព័ន្ធឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ហើយនិងកែលំអប្រព័ន្ធគ្រប់គ្រងតុលាការគ្រប់ជាន់ថ្នាក់។

១១- ការកែទម្រង់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប)

១២- ការបញ្ឈប់ការយកប្រាក់នៅលើផ្លូវជាតិលេខ៤ ដែលជាជំនួយរបស់សហរដ្ឋអាមេរិក។

១៣- ការពិនិត្យឡើងវិញលើកិច្ចព្រមព្រៀងដាក់ឱ្យធ្វើអាជីវកម្មលើប្រាសាទអង្គរវត្ត

១៤- ការផ្តល់ប្រាក់កំចីដោយយកការប្រាក់ទាប។

១៥- ការបញ្ឈប់ឡូតឺនេសាទពាណិជ្ជកម្មមួយរយៈ ដើម្បីថែរក្សាមច្ឆាជាតិ

១៦- ការបញ្ឈប់កិច្ចសន្យាព្រៃសម្បទាន ដើម្បីស្តារព្រៃឈើ

១៧- ការជម្រុញឯកជនភាវូបនីយកម្មចំការកៅស៊ូ

១៨- ការបង្កើតភូមិអភិវឌ្ឍន៍ និងសាងសង់ផ្លូវគមនាគមន៍ តាមបណ្តោយព្រំដែន

១៩- ការបញ្ឈប់ឈ្មួញរកស៊ីផ្តាច់មុខ

២0- ការដោះស្រាយបញ្ហាដែនទឹក និងដែនអាកាស

២១- ការសើរើពិនិត្យលើអាជ្ញាប័ណ្ណស្រាវជ្រាវរ៉ែ លោហធាតុ និងត្បូងថ្មមានតម្លៃដែលយក ទៅធ្វើអាជីកម្មដោយខុសច្បាប់ជាដើម។

XV - រសៀល**<u>ថ្ងៃទី ២៨ មេសា ២០០៤</u>** ក្រុមការងារគណបក្សទាំងពីរ បានជួបគ្នាជាលើកទីប្រាំពីរ តាមការគ្រោងទុកនៅកន្លែងដដែល។ ជាលទ្ធផល ក្រុមការងារនៃគណបក្សទាំងពីរបានឯកភាពលើ១០ចំនុចបន្ថែមទៀត ដូច្នេះចំនុចដែលនៅសល់ គឺមានចំនួន១៣។

ចំនុចសំខាន់ៗដែលមិនទាន់ត្រូវ រួមមាន

- គណបក្សប្រជាជនកម្ពុជា ទាមទារឱ្យរក្សាទុកគណៈកម្មាធិការសិទ្ធិមនុស្សរបស់រាជរដ្ឋាភិបាលបន្ថែមលើគណៈកម្មាធិការជាតិសិទ្ធិមនុស្សដែលនឹងបង្កើតឡើងថ្មី។ មូលហេតុ: ស្ថាប័នជាតិធំៗដូចជារដ្ឋសភា ព្រឹទ្ធសភា រួមទាំងសង្គមស៊ីវិលផងត្រូវមានគណៈកម្មាធិការសិទ្ធិមនុស្សរៀងៗខ្លួន។

- គណបក្សហ៊ុនស៊ុនបិច:លុបចោលគណៈកម្មាធិការសិទ្ធិមនុស្សរបស់រាជរដ្ឋាភិបាល ជំនួសដោយគណៈកម្មាធិការជាតិសិទ្ធិមនុស្សដែលនឹងបង្កើតឡើងថ្មី។ ក្នុងបណ្តាប្រទេសទាំងអស់នៅលើពិភពលោកគ្មានប្រទេសណាដែលរដ្ឋាភិបាលមានគណៈកម្មាធិការសិទ្ធិមនុស្សការពារខ្លួនឯងនោះទេ។

- នាយករដ្ឋមន្ត្រី និងសមាជិករាជរដ្ឋាភិបាលអញ្ជើញទៅឆ្លើយដោយផ្ទាល់មាត់នៅចំពោះមុខរដ្ឋសភាមួយខែម្តង។

- វេទិការាស្ត្រ និងមន្ត្រី បីខែម្តង។

- ច្បាប់ផងទាំងឡាយដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ត្រូវបង្កើតឱ្យបានមុនដំណាច់ឆ្នាំ ២០០៦។

- ការស្នើឱ្យមានថវិកាស្វយ័តសំរាប់គណបក្សប្រឆាំង។

- បញ្ហាពាក់ព័ន្ធជាមួយប្រាក់ជំនួយដល់អង្គការមិនមែនរដ្ឋាភិបាល។

- ការតម្លើងប្រាក់ប្រៀវត្សឱ្យបាន ១០០ ដុល្លាយ៉ាងតិចជូនមន្ត្រីរាជការ រួមទាំងទាហាន ប៉ូលីស។

- ការលុបចោលកិច្ចព្រមព្រៀងព្រំដែន ១៩៧៩ ១៩៨២ ១៩៨៣ ១៩៨៥ ខុសច្បាប់ជាមួយប្រទេសជិតខាង។

- ការបញ្ឈប់តម្លៃប្រេងឥន្ធនៈឱ្យនៅប្រហាក់ប្រហែលនឹងប្រទេសជិតខាង (១៤00រៀលក្នុងមួយលីត្រ)។

- ការតម្លើងប្រាក់ខែ រួមទាំងប្រាក់កម្រៃសន្តិសុខសង្គមឱ្យបាន៧0ដុល្លាក្នុងមួយខែជូនកម្មករសំរាកចក្រ។

- ការកែទម្រង់រចនាសម្ព័ន្ធឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ហើយនិងកែលំអប្រព័ន្ធគ្រប់គ្រងតុលាការគ្រប់ជាន់ថ្នាក់។

- សុំឱ្យនគរបាលយុត្តិធម៌ប្រតិបត្តិការ ឋិតនៅក្រោមការគ្រប់គ្រងត្រួតពិនិត្យរបស់ក្រសួងយុត្តធម៌។

- ការបញ្ឈប់ការយកប្រាក់នៅលើផ្លូវជាតិលេខ៤ ដែលជាជំនួយរបស់សហរដ្ឋអាមេរិក។

ភាគីទាំងពីរក៏បានសំរេចផងដែរថា នឹងបង្កើនល្បឿនដំណើរការចរចា។ កិច្ចប្រជុំពិភាក្សាបន្ត បន្ទាប់នឹងគ្រោង ធ្វើនៅថ្ងៃទី ២៩ និង ៣០ មេសា ២០០៤ ទាំងពេលព្រឹក និងពេលរសៀល។

XVI - <u>ថ្ងៃទី ២៩ មេសា ២០០៤</u> ក្រុមការងារគណបក្សទាំងពីរ បានជួបគ្នាជាលើកទីប្រាំបី តាមការគ្រោងទុកនៅកន្លែងដដែល។ ជាលទ្ធផល ក្រុមការងារនៃគណបក្សទាំងពីរពុំបានឯកភាពលើចំនុចបន្ថែមទៀតទេ។

មន្ត្រីអ្នកនាំពាក្យគណបក្សប្រជាជនកម្ពុជា បានមានប្រសាសន៍ឱ្យដឹងអំពីលទ្ធផលនៃកិច្ចប្រជុំនៅថ្ងៃនេះថា ក្រុមការងារនៃគណបក្សទាំងពីរបានពិភាក្សា បានលើកចំណុចទាក់ទងជាមួយការគ្រប់គ្រងថវិការបស់អង្គការក្រៅរដ្ឋាភិបាលទាំងអស់ បញ្ហាកែទម្រង់តុលាការ និងតែងតាំងចៅក្រម។

ឯកឧត្តម ខៀវ កាញារីទ្ធ អ្នកនាំពាក្យគណបក្សប្រជាជនកម្ពុជា បានមានប្រសាសន៍ឱ្យដឹងថា នៅក្នុងកិច្ចប្រឹងប្រែងប្រជុំទាំងព្រឹក និងល្ងាចនៅថ្ងៃនេះថា ក្រៅពីចំណុចទាំង១០ ដែលបានឯកភាពគ្នា និងបានកែសម្រួលពាក្យពេចន៍នោះ ក្រុមការងារគណបក្សទាំងពីរនៅមានបញ្ហាមួយចំនួនដែលបានជជែកគ្នាហើយនៅតែមិនទាន់ចុះសម្រុងជាមួយគ្នា។

ទាក់ទងជាមួយបញ្ហាកែទម្រង់តុលាការវិញ ឯកឧត្តម ខៀវ កាញារីទ្ធ បាននិយាយថា ការរើសចៅក្រម គឺឆ្លងតាមការប្រឡង និងការបណ្តុះបណ្តាល មិនមែនតែងតាំងតាមរយៈគណបក្ស ដូចគណបក្សហ៊ុនសុនបុិចស្នើនោះទេ។

នៅក្នុងពេលជួបជាមួយអ្នកកាសែតនេះ ឯកឧត្តម នៅ កាស៊ី អ្នកនាំពាក្យគណបក្សហ៊ុនសុនបុិច មិនបានមានវត្តមានទេ ដោយលោកបានជិះឡានចាកចេញទៅ។

ការប្រជុំក្រុមការងារនេះ នឹងធ្វើជាបន្តទៀតនៅថ្ងៃសុក្រទាំងព្រឹក ទាំងល្ងាចជាបន្តទៀត។

XVII - <u>ថ្ងៃទី ៣០ មេសា ២០០៤</u> ក្រុមការងារគណបក្សទាំងពីរបានជួបគ្នា ជាលើកទីប្រាំបួន តាមការគ្រោងទុកនៅកន្លែងដដែល។ ជាលទ្ធផល ក្រុមការងារនៃគណបក្សទាំងពីរនៅតែមិនទាន់អាចសំរេចលើការយល់ព្រមគ្នាទាំងស្រុង ដើម្បីឈានទៅរកការបង្កើតរចនាសម្ព័ន្ធដឹកនាំរដ្ឋសភា និងរាជរដ្ឋាភិបាលថ្មី។

មន្ត្រីអ្នកនាំពាក្យគណបក្សហ៊ុនសុនបុិច ឯកឧត្តម នៅ កាស៊ី បាននិយាយថា បញ្ហាធំៗដែលនៅសេសសល់ រួមមាន បញ្ហាព្រំប្រទល់ដែន និងការកែទម្រង់ប្រព័ន្ធតុលាការ នឹងត្រូវបង្វែរដាក់ទៅឱ្យប្រមុខអ្នកដឹកនាំនយោបាយ ដើម្បីជួបធ្វើការចរចាកំពូលរវាងគ្នា និងគ្នាដើម្បីសំរេចបន្តទៅទៀត។

មន្ត្រីគណបក្សទាំងពីរ បាននិយាយថា ការចរចាអំពីបញ្ហាគោលនយោបាយសំរាប់រដ្ឋាភិបាលថ្មីនៅតែប្រឈមមុខការតឹងតែងនៅឡើយ ជាពិសេសគឺបញ្ហាព្រំដែន និងការកែទម្រង់ស្ថាប័នផ្សេងៗ។

ឯកឧត្តម ខៀវ កាញារីទ្ធ អ្នកនាំពាក្យរបស់គណបក្សប្រជាជនកម្ពុជា និងឯកឧត្តម នៅ កាស៊ី អ្នកនាំពាក្យក្រុមការងាររបស់គណបក្សហ៊ុនសុនបុិចបានមានប្រសាសន៍ក្រោយកិច្ចប្រជុំកាលពីថ្ងៃត្រង់នេះ

ថា ដំណើរការចរចា គឺមានបរិយាកាសល្អ ប៉ុន្តែគេនៅតែឃើញមានចំណុចសំខាន់ៗជាច្រើនស្ថិតក្នុងការពិភាក្សាដ៏តានតឹងដដែល ។

ឯកឧត្តម នៅ កាស៊ុ បានបញ្ជាក់ថា តាមមើលទៅអាចមានចំណុចមួយចំនួន ត្រូវដាក់ជូនមេដឹកនាំកំពូលជាអ្នកសម្រេច ដោយរួមានទាំងបញ្ហាព្រំដែន និងការកែទម្រង់តុលាការ ។

ទោះជាយ៉ាងណាក៏ដោយ ឯកឧត្តម ខៀវ កាញារីទ្ធ បានថ្លែងថា មានការព្រមព្រៀងគ្នាលើចំណុចជាច្រើនហើយអំពីគោលនយោបាយរដ្ឋាភិបាលថ្មីនោះ ។

មន្ត្រីអ្នកនាំពាក្យទាំងពីរមិនបានបញ្ជាក់ច្បាស់លាស់ទេថា តើនៅមានចំណុចសេសសល់ប៉ុន្មានក្នុងចំណោមសេចក្តីព្រាង៧ពាំចំណុចនៃគោលនយោបាយរដ្ឋាភិបាលថ្មីដែលបានដាក់ចូលក្នុងការចរចានោះ ។

ឧបសម្ព័ន្ធ ៣: របាយការណ៍លំអិត ស្តីពីសកម្មភាពរបស់រដ្ឋសភា

១. ដំណើរការសម័យប្រជុំ និងស្ថានភាពនៅមន្ទីរសភា

យោងតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៨២: *"រដ្ឋសភាបើកសម័យប្រជុំដំបូង ហុកសិបថ្ងៃយ៉ាងយូរក្រោយពេលបោះឆ្នោតតាមការកោះប្រជុំរបស់ព្រះមហាក្សត្រ..."*។ រដ្ឋមន្ត្រីព្រះបរមរាជវាំង បានចេញលិខិតកោះអញ្ជើញសមាជិកសភាជាប់ឆ្នោតទាំងអស់ ដើម្បីបើកសម័យប្រជុំដំបូងនៅថ្ងៃទី២៧ កញ្ញា ឆ្នាំ២០០៣។ មានតែសមាជិកសភាជាប់ឆ្នោតមកពីគណបក្សប្រជាជនកម្ពុជាចំនួន៧៣រូប ប៉ុណ្ណោះបានចូលរួមក្នុងកិច្ចប្រជុំនេះ ចំណែកឯសមាជិកសភានៃគណបក្សហ៊្វុនស៊ិនប៉ិច និងគណបក្សសមរង្ស៊ីបានធ្វើពហិកាមិនចូលរួមទេ។ សម្តេច ជា ស៊ីម ក្នុងព្រះរាជតំណាងព្រះមហាក្សត្របានអាននូវសុន្ទរកថាខ្លីមួយ ដើម្បីប្រកាសបើកសម័យប្រជុំសភា។ ប៉ុន្តែ សមាជិកសភាដែលបានចូលរួមទាំង៧៣រូបនោះ មិនទាន់បានធ្វើពិធីស្បថសច្ចាប្រណិធានទេ។ គណបក្សហ៊្វុនស៊ិនប៉ិច និងគណបក្សសមរង្ស៊ីបាននិយាយថា ការធ្វើពហិការរបស់ពួកគេ គឺឆ្លុះបញ្ចាំងទៅលើបណ្តឹងចំពោះគណបក្សប្រជាជនកម្ពុជា ដែលមិនត្រូវបានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ដោះស្រាយ។

សមាជិកសភាជាប់ឆ្នោតមកពីគណបក្សប្រជាជនកម្ពុជាទាំង៧៣រូបចូលរួម
បើកសម័យប្រជុំដំបូងនៅថ្ងៃទី២៧ កញ្ញា ឆ្នាំ២០០៣ នៅឯមន្ទីររដ្ឋសភាជាតិ

បើយោងតាមរដ្ឋធម្មនុញ្ញមាត្រា៨២ នោះ ការបើកសម័យប្រជុំដំបូង ដើម្បីទទួលសុពលភាពនោះ គឺលើសចំនួន៦០ថ្ងៃ បើគិតចាប់ពីថ្ងៃបោះឆ្នោតថ្ងៃ២៧ កក្កដា ដល់ថ្ងៃ៤ តុលា ២០០៣ ជាថ្ងៃដែលសមាជិកសភាជាប់ឆ្នោតទាំងអស់បានចូលស្បថនៅក្នុងព្រះបរមរាជវាំង ក្រោមព្រះរាជាអធិបតីភាពព្រះមហាក្សត្រ ព្រមទាំងសម្តេចព្រះសង្ឃរាជទាំងពីរគណៈ។

គិតមកដល់ខែមេសា ឆ្នាំ ២០០៤នេះ មានការប្រជុំសភាតែម្តងប៉ុណ្ណោះគឺនៅថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០០៣ ដែលរដ្ឋសភាបានបើកសម័យប្រជុំដំបូងរបស់ខ្លួន ក្រោមអធិបតីភាព ឯកឧត្តម ជា សុទ្ធ ព្រឹទ្ធបុរសសមាជិកសភា ដើម្បីធ្វើការប្រកាសសុពលភាព នៃអណត្តិរបស់សមាជិកសភា ហើយនិងមិនទាន់មានរចនាសម្ព័ន្ធរបស់ខ្លួននៅឡើយ ។

មានសេចក្តីព្រាងច្បាប់ និងសេចក្តីស្នើច្បាប់ប្រមាណ៤៩អត្ថបទ ដែលបានតាក់តែងឡើងដោយរាជរដ្ឋាភិបាល និងតំណាងរាស្ត្រកំពុងជាប់គាំងនៅរដ្ឋសភាជាតិ។ ក្នុងនោះមានសេចក្តីព្រាងច្បាប់ និងសេចក្តីស្នើច្បាប់ចំនួន៣០ កំពុងស្ថិតនៅឯគណៈកម្មការជំនាញនានារបស់រដ្ឋសភា និងសេចក្តីព្រាងច្បាប់ចំនួន១៩ ទៀតកំពុងស្ថិតនៅឯគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា។ សេចក្តីព្រាងច្បាប់ទាំងនោះ សុទ្ធសឹងជាច្បាប់សំខាន់ៗ ដូចជា: សេចក្តីព្រាងច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋ ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ និងសេចក្តីស្នើច្បាប់ចាំបាច់ និងបន្ទាន់មួយចំនួនទៀត ដែលក្នុងនោះរួមជាមួយនឹងការធ្វើឱ្យកម្ពុជាពេញលក្ខណៈ សម្រាប់ការចូលរួមជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ។

គួរឱ្យកត់សំគាល់ផងដែរថា ចាប់តាំងពីខែតុលា ២០០៣ រហូតមកដល់ខែមេសា ២០០៤នេះ តំណាងរាស្ត្រជាប់ឆ្នោតថ្មីទាំងនោះ ពុំទាន់ទទួលបាននូវប្រាក់ប្រៃវត្ស និងសោហ៊ុយបេសកកម្មទេ។ <u>ប៉ុន្តែ តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាត្រូវបានលើកទឹកចិត្តឱ្យខ្ជីប្រាក់ឧបត្ថម្ភពីគណបក្សខ្លួន។</u>

មានពត៌មានស្តីពីករណីពុករលួយ ការកេងប្រវ័ញ្ច និងការប្រកាន់បក្សពួកក្នុងស្ថាប័ននីតិបញ្ញត្តិនេះ រួមមាន ការជ្រើសរើសបុគ្គលិក (មានបុគ្គលិកខ្មោច គ្មាននីតិវិធីច្បាស់លាស់ក្នុងការជ្រើសរើស) ការកិបកេងចំណាយ ហើយករណីធំជាងគេនោះគឺការដេញថ្លៃសាងសង់រដ្ឋសភាថ្មី (យោងសំដីរបស់ ឯកឧត្តម សុន ឆ័យ)។

ក្នុងខែមីនា ២០០៤ នេះ មានពត៌មានស្តីពីការខ្វះសម្ភារៈការិយាល័យនៅក្នុងមន្ទីរដ្ឋសភា ដូចជាក្រដាសសរសេរជាដើម ។

២. អំពីការចុះបេសកកម្មរបស់តំណាងរាស្ត្រ

ក្នុងអំឡុងពេលនេះ តំណាងរាស្ត្រជាប់ឆ្នោតអាណត្តិទី៣ ទាំង១២៣រូប ពុំទាន់ទទួលបាននូវប្រាក់ប្រៀវត្សប្រាក់បេសកកម្ម ហើយរដ្ឋសភាពុំទាន់មានរចនាសម្ព័ន្ធនៅឡើយទេ ដែលជាកត្តាមួយជះឥទ្ធិពលនាំឱ្យមានភាពអសកម្ម និងមិនដំណើរការ លើការបំពេញតួនាទី និងភារកិច្ចរបស់ខ្លួនជាតំណាងរាស្ត្រ។ បើទោះបីជាយ៉ាងណាក៏ដោយ យើងសង្កេតឃើញថា មានតំណាងរាស្ត្រចំនួន៤៦រូប ស្មើនឹង៣៧% ក្នុងចំណោមតំណាងរាស្ត្រជាប់ឆ្នោតថ្មី ទាំង១២៣រូប បានចុះទៅមូលដ្ឋានមណ្ឌលខេត្ត/ក្រុងរបស់ខ្លួនក្នុងគោលបំណងផ្សេងៗពីគ្នា ដូចជាដើម្បីពង្រឹងបណ្តាញ និងដោះស្រាយបញ្ហាផ្ទៃក្នុងគណបក្ស ចុះសួរសុខទុក្ខ សំណេះសំណាលជាមួយអាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋជួយអន្តរាគមន៏ ដោះស្រាយបញ្ហាក្នុងមូលដ្ឋាន ចែកអំណោយ សម្ពោធសមិទ្ធិផលនានា រួមមានអណ្តូងទឹក សាលារៀន វត្តអារាម មន្ទីរពេទ្យ ផ្លូវថ្នល់..។ល។ ក្នុងខេត្ត/ក្រុងចំនួន១៨ ដែលរួមមាន១៩០លើក។ ប៉ុន្តែការចុះជួយធ្វើអន្តរាគមន៏ដោះស្រាយបញ្ហារបស់ប្រជាពលរដ្ឋមានចំនួនត្រឹម១៥លើកប៉ុណ្ណោះ។ បញ្ហាទាំងនោះមានដូចជា: ជម្លោះដីធ្លី ស្តារប្រឡាយ ជីកស្រះ បញ្ចុះតម្លៃ អគ្គិសនីជាដើម។

- គោលបំណងនៃការចុះបេសកកម្មនោះរួមមាន:
  - ចុះជួយអន្តរាគមន៏ដោះស្រាយបញ្ហា ដែលកើតឡើងនៅក្នុងមណ្ឌលរបស់ខ្លួនចំនួន១៥លើក។
    ក្នុងនោះ
    - តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាបានចុះ ចំនួន ៧ លើក
    - តំណាងរាស្ត្រគណបក្សហ៊្វុនស៊ិនប៉ិចបានចុះ ចំនួន ១ លើក
    - តំណាងរាស្ត្រគណបក្សសមរង្ស៊ីបានចុះ ចំនួន ៧ លើក
  - ចុះជួបសួរសុខទុក្ខ ចែកអំណោយប្រជាពលរដ្ឋ អាជ្ញាធរមូលដ្ឋាន ផ្តើមការកសាង និងសម្ពោធសមិទ្ធិផលនានាចំនួន១៣០លើក។
    ក្នុងនោះ
    - តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាបានចុះចំនួន៧១ លើក
    - តំណាងរាស្ត្រគណបក្សហ៊្វុនស៊ិនប៉ិចបានចុះ ចំនួន១០លើក
    - តំណាងរាស្ត្រគណបក្សសមរង្ស៊ីបានចុះ ចំនួន៤៩លើក
  - ចុះពង្រឹងបណ្តាញ ដោះស្រាយបញ្ហាផ្ទៃក្នុងគណបក្ស ចំនួន២៨លើក។
    ក្នុងនោះ

- តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាបានចុះ ចំនួន៦លើក
- តំណាងរាស្ត្រគណបក្សហ៊្វុនស៊ិនប៉ិចបានចុះ ចំនួន១៤លើក
- តំណាងរាស្ត្រគណបក្សសមរង្ស៊ីបានចុះ ចំនួន៨លើក

o ចូលរួមក្នុងកិច្ចប្រជុំ ឬវេទិកាពិភាក្សានានាដូចជាវេទិកាសាធារណៈ ដែលរៀបចំឡើងដោយអង្គការក្រៅរដ្ឋាភិបាល ចំនួន៨លើក ។

ក្នុងនោះ

- តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាបានចុះ ចំនួន១លើក
- តំណាងរាស្ត្រគណបក្សហ៊្វុនស៊ិនប៉ិចបានចុះ ចំនួន៣លើក
- តំណាងរាស្ត្រគណបក្សសមរង្ស៊ីបានចុះ ចំនួន៤លើក

o ចុះរឿងផ្ទាល់ខ្លួន ចំនួន៥លើក(នៃការចុះបេសកកម្មទាំង១៥0លើក) ។

ក្នុងបេសកកម្មទាំង១៥0លើករបស់តំណាងរាស្ត្រ**ខុមហ្វ្រែល** មិនបានផ្តោតចំពោះបេសកកម្ម រឿងផ្ទាល់ខ្លួនរបស់តំណាងរាស្ត្រទេ ដូច្នេះចំនួនបេសកម្មដែលមានសារៈប្រយោជន៍ដល់រាស្ត្រ និងមានចំនួនតែ ១៨១លើកប៉ុណ្ណោះដែលក្នុងនោះមាន :

- ក្នុងចំណោមតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាជាប់ឆ្នោតចំនួន៧៣នាក់ មានតំណាងរាស្ត្រចំនួន ២៣នាក់ ត្រូវជា៣២% បានចុះបេសកកម្មចំនួន៩១ ដង ទៅមណ្ឌលខេត្ត/ក្រុងរបស់ខ្លួន ។
- ក្នុងចំណោមតំណាងរាស្ត្រគណបក្សហ៊្វុនស៊ិនប៉ិចជាប់ឆ្នោតចំនួន២៦នាក់ មានតំណាងរាស្ត្រចំនួន១0 នាក់ត្រូវជា៣៨%បានចុះបេសកកម្មចំនួន៣៤ដង ទៅមណ្ឌលខេត្ត/ក្រុងរបស់ខ្លួន ។
- ក្នុងចំណោមតំណាងរាស្ត្រគណបក្សសមរង្ស៊ីជាប់ឆ្នោតចំនួន២៤នាក់ មានតំណាងរាស្ត្រចំនួន១៣នាក់ ត្រូវជា៥៤% បានចុះបេសកកម្មចំនួន៦៥ដង ទៅមណ្ឌលខេត្ត/ក្រុងរបស់ខ្លួន ។
- ខេត្ត/ក្រុងដែលតំណាងរាស្ត្រទាំងនោះបានចុះបេសកកម្មមានដូចជា: ខេត្តបន្ទាយមានជ័យ បាត់ដំបង កណ្តាល កំពង់ចាម កំពង់ឆ្នាំង កំពង់ស្ពឺ កំពង់ធំ កំពត កោះកុង មណ្ឌលគីរី ព្រះវិហារ ព្រៃវែង ពោធិ៍សាត់ រតនគីរី ក្រុងព្រះសីហនុ ស្វាយរៀង តាកែវ និងក្រុងប៉ៃលិន។ ចំណែកឯតំណាងរាស្ត្រក្នុង៦ខេត្ត/ក្រុងផ្សេងទៀត បណ្តាញខេត្ត/ក្រុង**ខុមហ្វ្រែល** ពុំទាន់បានទទួលបានពត៌មានពីតំណាងរាស្ត្រទាំងនោះនៅឡើយទេ។ បច្ចុប្បន្ននេះ **ខុមហ្វ្រែល** បាននឹងកំពុងប្រមូលពត៌មានបន្តទៀត ។

៣. តារាងបញ្ជាញ្ចូចំនួនដែលតំណាងរាស្ត្រចានចុះបេសកកម្ម (ពីច្រើនទៅតិច)

ល.រ	ឈ្មោះអ្នកតំណាងរាស្ត្រ	គណបក្ស	មណ្ឌល	ចំនួនលើក
១	ឯកឧត្តម ង៉ោ សុវណ្ណ	សមរង្ស៊ី	កណ្តាល	១៥
២	ឯកឧត្តម ជ្រា សុចិន្តា	សមរង្ស៊ី	កណ្តាល	១៥
៣	ឯកឧត្តម សួស ការណារ	ប្រជាជន	ក្រុងព្រះសីហនុ	១២
៤	ឯកឧត្តម ម៉ម ប៊ុនឆាង	ហ៊្វុនស៊ិនប៉ិច	កំពត	១១
៥	លោកជំទាវ លី គីមលៀង	ប្រជាជន	បាត់ដំបង	១១
៦	ឯកឧត្តម ឆេស ហ៊ាញ	ប្រជាជន	បាត់ដំបង	៩
៧	ឯកឧត្តម ស ខេង	ប្រជាជន	បាត់ដំបង	៩
៨	ឯកឧត្តម ចាន់ ចេង	សមរង្ស៊ី	កណ្តាល	៨
៩	ឯកឧត្តម ថាន់ ស៊ីណា	ហ៊្វុនស៊ិនប៉ិច	កំពត	៨
១០	ឯកឧត្តម ស៊ុយ សែម	ប្រជាជន	ពោធិ៍សាត់	៨
១១	ឯកឧត្តម អេង ឆៃអ៊ាង	សមរង្ស៊ី	បាត់ដំបង	៧
១២	ឯកឧត្តម ឌឹម ថូត	ប្រជាជន	បាត់ដំបង	៧
១៣	ឯកឧត្តម លី ធុជ	ហ៊្វុនស៊ិនប៉ិច	ពោធិ៍សាត់	៥
១៤	លោកជំទាវ ជួញ សុខឆៃ	ប្រជាជន	បាត់ដំបង	៥
១៥	ឯកឧត្តម តន់ ង៉ាន់ថារ៉ា	សមរង្ស៊ី	បាត់ដំបង	៤
១៦	ឯកឧត្តម ប៊ូ ថង	ប្រជាជន	រតនគីរី	៤
១៧	ឯកឧត្តម សុក ផេង	សមរង្ស៊ី	កំពង់ធំ	៤
១៨	លោកជំទាវ សោម គីមសួគី	ប្រជាជន	កំពត	៤
១៩	ឯកឧត្តម វ៉ែត សារ៉ឹម	ប្រជាជន	មណ្ឌលគីរី	៣

២០	**ឯកឧត្តម សម រង្ស៊ី**	សមរង្ស៊ី	កំពង់ចាម	៣
២១	**ឯកឧត្តម ជាម យៀប**	ប្រជាជន	ព្រៃវែង	៣
២២	**ឯកឧត្តម ង៉ោ ប៊ុនស្រ៊ី**	ហ៊្វុនស៊ិនប៊ិច	កំពង់ធំ	៣
២៣	**ឯកឧត្តម អ៊ុន ឆឺង**	ប្រជាជន	កំពង់ធំ	២
២៤	**ឯកឧត្តម ម៉ី ណាន**	ប្រជាជន	ពោធិ៍សាត់	២
២៥	**ឯកឧត្តម ញ៉ៅប ប៊ុនជិន**	ហ៊្វុនស៊ិនប៊ិច	បន្ទាយមានជ័យ	២
២៦	**ឯកឧត្តម ញឹម វណ្ណដា**	ប្រជាជន	ព្រៃវែង	២
២៧	**ឯកឧត្តម ជាម ចំន្ទនី**	សមរង្ស៊ី	កំពង់ចាម	២
២៨	**ឯកឧត្តម ជា ប៉ូច**	សមរង្ស៊ី	ព្រៃវែង	២
២៩	**ឯកឧត្តម ម៉ៅ មុនីវណ្ណ**	សមរង្ស៊ី	កំពង់ចាម	២
៣០	**ឯកឧត្តម ស៊ុក សំអេង**	ប្រជាជន	ព្រះវិហារ	២
៣១	**ឯកឧត្តម គឹម សួរគីរិទ្ធ**	សមរង្ស៊ី	បន្ទាយមានជ័យ	១
៣២	**ឯកឧត្តម ឃូ ហុកគ្រី**	ហ៊្វុនស៊ិនប៊ិច	កំពង់ចាម	១
៣៣	**ឯកឧត្តម សំ សាន**	ប្រជាជន	ប៉ៃលិន	១
៣៤	**ឯកឧត្តម សាយ ឈុំ**	ប្រជាជន	កំពង់ស្ពឺ	១
៣៥	**ឯកឧត្តម សុខ សាន**	ហ៊្វុនស៊ិនប៊ិច	កំពង់ឆ្នាំង	១
៣៦	**ឯកឧត្តម ជិន ប៊ុនសាន**	ប្រជាជន	ពោធិ៍សាត់	១
៣៧	**ឯកឧត្តម ង៉ោ ង្វ**	ប្រជាជន	កំពង់ធំ	១
៣៨	**ឯកឧត្តម អាយ ខន**	ប្រជាជន	កោះកុង	១
៣៩	**ឯកឧត្តម ហោ ណាំហុង**	ប្រជាជន	កំពង់ចាម	១
៤០	**ឯកឧត្តម ក្បៀង ង៉ាន**	សមរង្ស៊ី	កំពត	១

៤១	**ឯកឧត្តម នុត រំដួល**	សមរង្សុី	កំពង់ស្ពឺ	១
៤២	**ឯកឧត្តម ម៉ោញ សាផាន**	ហ៊ុនសុិនប៊ិច	កំពង់ចាម	១
៤៣	**សម្តេច ហេង សំរិន**	ប្រជាជន	កំពង់ចាម	១
៤៤	**លោកជំទាវ ជួង ឥណ្ណា**	ប្រជាជន	ស្វាយរៀង	១
៤៥	**ឯកឧត្តម កុល ផេង**	ហ៊ុនសុិនប៊ិច	តាកែវ	១
៤៦	**លោកជំទាវ គី លំអង**	ហ៊ុនសុិនប៊ិច	បាត់ដំបង	១
	សរុប			**១៩០**

៤- អំពីទំនាក់ទំនងរវាងប្រជាពលរដ្ឋម្ចាស់ឆ្នោត ជាមួយតំណាងរាស្ត្រខ្លួន

ប្រជាពលរដ្ឋនៅបណ្តាខេត្ត/ក្រុងមួយចំនួន បានតួញ្ចែរអំពីការលំបាកក្នុងការធ្វើទំនាក់ទំនងផ្តល់ពត៌មាន សុំអន្តរាគមន៍ពីសំណាក់តំណាងរាស្ត្ររបស់ខ្លួន។ បញ្ហាទាំងនោះបណ្តាលមកពី:

- ការិយាល័យតំណាងរាស្ត្រនៅតាមមណ្ឌលខេត្ត/ក្រុងស្ទើរទាំងអស់ពុំមានដំណើរការអ្វីទេ គឺមានតែបុគ្គលិកម្នាក់ ឬពីរនាក់នៅប្រចាំការប៉ុណ្ណោះ។
- ម្យ៉ាងវិញទៀត តំណាងរាស្ត្រប្រហែល៩0%មានទីលំនៅ ឬស្នាក់នៅជាអចិន្ត្រៃយ៍នៅឯរាជធានីភ្នំពេញ ជាហេតុធ្វើឱ្យប្រជាពលរដ្ឋក្នុងមណ្ឌល មានការលំបាកក្នុងការស្នើសុំការអន្តរាគមន៍ដោះស្រាយនៅពេលមានបញ្ហាកើតមានឡើង។ យោងតាមពត៌មានបានបង្ហាញឱ្យដឹងថា មានតំណាងរាស្ត្រប្រមាណតែជាង ១0 រូបប៉ុណ្ណោះ ដែលបានស្នាក់នៅជាប់លាប់ក្នុងមណ្ឌលខេត្ត/ក្រុងរបស់ខ្លួន។

ជាឧទាហរណ៍ជាក់ស្តែង ក្នុងខែមីនា ២00៤នេះ មានប្រជាពលរដ្ឋប្រមាណ១៦៦នាក ់មកពីស្រុកគូលែន ខេត្តព្រះវិហារ បានសុំឱ្យតំណាងរាស្ត្រជួយអន្តរាគមន៍ដោះស្រាយប្រាក់ពលីកងទ័ព។ ប៉ុន្តែគេពុំឃើញវត្តមានតំណាងរាស្ត្រទេ ព្រោះភាគច្រើនគាត់ឋិតនៅទីក្រុងភ្នំពេញ។

៥- ការទំនាក់ទំនងរវាងតំណាងរាស្ត្រ និងរាជរដ្ឋាភិបាលបច្ចុប្បន្ន (រដ្ឋាភិបាលចាំផ្ទះ)

បើយោងតាមស្មារតីរដ្ឋធម្មនុញ្ញ និងច្បាប់នានាដែលមានជាធរមាន នាពេលបច្ចុប្បន្ននេះ មិនមានការបញ្ជាក់ច្បាស់អំពីទំនាក់ទំនងរវាងសភាថ្មី និងរដ្ឋាភិបាលចាំផ្ទះដើម្បីរៀបចំចក្ខវិកាស្វយ័តរបស់សភា និងរយៈពេលនៃដំណើរការ "រដ្ឋាភិបាលចាំផ្ទះ"ទេ ដែលជាហេតុធ្វើឱ្យតំណាងរាស្ត្រជាប់ឆ្នោតថ្មីពុំមានឥទ្ធិពលត្រួតពិនិត្យទៅលើ

ស្ថាប័នរដ្ឋាភិបាលបច្ចុប្បន្ន។ ដូចនេះរដ្ឋាភិបាលបច្ចុប្បន្នបានបដិសេធមិនច្បាស់លាស់ថា មិនផ្តល់ថវិកាសូយ័តសំរាប់ប្រាក់បំណាច់ និងចំណាយលើដំណើរការការងារសភា ដោយគ្រាន់តែយកហេតុផលថា សភាគ្មានរចនាសម្ព័ន្ធនៅឡើយ។

៦. ការបញ្ជៀសតិ អំពាវនាវ/ស្នើវិធានការ និងការដាក់សំនួរ របស់តំណាងរាស្ត្រ

មានតំណាងរាស្ត្រមួយចំនួន ជាពិសេសមកពីគណបក្សសមរង្ស៊ី បានធ្វើសេចក្តីស្នើច្បាប់ ការលើកជាការព្រួយបារម្ភ ការដាក់ពាក្យប្តឹង ការផ្ញើលិខិតអន្តរាគមន៍សុំចាត់វិធានការ សុំការបកស្រាយច្បាប់នានាចំនួន៣០លើក ទៅស្ថាប័នមានសមត្ថកិច្ច ដូចជា:

១- ថ្ងៃទី២៥ វិច្ឆិកា ២០០៣ ឯកឧត្តម ជ្រា សុចិន្តា តំណាងរាស្ត្រមណ្ឌលកណ្តាល មកពីគណបក្សសមរង្ស៊ី បានផ្ញើលិខិតថ្វាយព្រះមហាក្សត្រ សំណើសុំព្រះរាជទាននូវព្រះរាជអំណោយថ្លៃថ្នា ដើម្បីសង្គ្រោះប្រជារាស្ត្រជាកូនចៅចំនួន៤៩៨គ្រួសារ រស់នៅក្នុងឃុំស្អាងភ្នំ ស្រុកស្អាងខេត្តកណ្តាល ដែលកំពុងខ្វះខាតស្បៀងធ្ងន់ធ្ងរ។

ពុំបានទទួលលិខិតឆ្លើយតបទេ ប៉ុន្តែឃើញមានក្រុមសម្តេចឱ្យចុះជួយដោះស្រាយផ្តល់ព្រះរាជអំណោយ។

២-ថ្ងៃទី២៩ ធ្នូ២០០៣ ឯកឧត្តម កែវ រ៉ៃមី តំណាងរាស្ត្រមណ្ឌលភ្នំពេញ មកពីគណបក្សសម រង្ស៊ី បានផ្ញើលិខិតទៅឯកឧត្តមសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងការបរទេសសំណើសុំជួយអន្តរាគមន៍ការពារសន្តិសុខដល់គណៈកម្មាធិការសម្របសម្រួលខ្មែរកម្ពុជាក្រោម ក្នុងការទាមទារសិទ្ធិបញ្ចេញមតិដង្ហែព្រះត្រ័យបិដកទៅកាន់វត្តទាំងបួននៅកម្ពុជាក្រោម និងសំណើសុំជួយអន្តរាគមន៍ទៅកាន់ស្ថានទូតវៀតណាមក្នុងគោលបំណងដង្ហែព្រះត្រ័យបិដកទៅកាន់វត្តទាំងបួននៅកម្ពុជាក្រោម។ សំណើនេះបានទទួលលិខិតឆ្លើយតបលេខ០៤៦ អស១/កបទ.សអ ចុះថ្ងៃទី៦ មករា ២០០៤ ចុះហត្ថលេខាដោយ ឯកឧត្តមអនុរដ្ឋលេខាធិការក្រសួងការបរទេស ឡុង វិសាលោ។

៣- ថ្ងៃទី១ មករា ២០០៤ ឯកឧត្តម កែវ រ៉ៃមី តំណាងរាស្ត្រមណ្ឌលភ្នំពេញ មកពីគណបក្សសមរង្ស៊ី បានផ្ញើលិខិតទៅឯកឧត្តម ស ខេង និងឯកឧត្តម យូ ហុកគ្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃដោយសុំផ្តល់អនុសាសន៍ ដើម្បីពិចារណាខាងគតិច្បាប់ ជុំវិញបញ្ហាបង្កើត និងចុះបញ្ជី "សមាគមវៀតណាមនៅក្នុងព្រះរាជាណាចក្រកម្ពុជា"។ សំណើនេះពុំបានទទួលបានការឆ្លើយតបទេ។

៤- ថ្ងៃទី១៦ កុម្ភៈ ២០០៤ ឯកឧត្តម សុន ឆ័យ តំណាងរាស្ត្រមណ្ឌលភ្នំពេញ មកពីគណបក្សសមរង្ស៊ី បានផ្ញើលិខិតទៅឯកឧត្តម ស ខេង និងឯកឧត្តម យូ ហុកគ្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ស្នើសុំលុបចោលជាបន្ទាន់នូវការអនុញ្ញាតឱ្យបង្កើត "សមាគមវៀតណាមនៅក្នុងព្រះរាជាណាចក្រកម្ពុជា" និងការអនុញ្ញាតឱ្យ "បើកទីស្នាក់ការសាខាសមាគមវៀតណាម នៅក្នុងព្រះរាជាណាចក្រកម្ពុជាក្នុងខេត្ត/ក្រុងទាំង១៩" តាមការ

១០- ថ្ងៃ១២ មីនា ២០០៤ ឯកឧត្តម សុក ផេង តំណាងរាស្ត្រមណ្ឌលកំពង់ធំ មកពីគណបក្ស សមរង្ស៊ី បានផ្ញើលិខិតទៅឯកឧត្តម ប្រធានអាជ្ញាធរអគ្គីសនីកម្ពុជា ស្នើចាត់វិធានការបញ្ចុះតម្លៃ និងទប់ស្កាត់ការប៉ុនប៉ងតម្លើងថ្លៃជាវអគ្គីសនីនៅខេត្តកំពង់ធំ។ ពុំទាន់មានការឆ្លើយតបនៅឡើយទេមកដល់ពេលនេះ។

១១- ថ្ងៃ១៥ មីនា ២០០៤ ឯកឧត្តម សុក ផេង តំណាងរាស្ត្រមណ្ឌលកំពង់ធំ មកពីគណបក្ស សមរង្ស៊ីបានផ្ញើលិខិតទៅ ឯកឧត្តម ណាំ ទុំ អភិបាលខេត្តកំពង់ធំ ស្នើចាត់វិធានការបញ្ឈប់ការលក់ព្រឡសម្បត្តិសាធារណៈដោយមេឃុំកំពង់ក្របៅ និងអាជ្ញាធរស្រុកស្ទឹងសែន។ ពុំទាន់មានការឆ្លើយតបនៅឡើយទេមកដល់ពេលនេះ។

១២- ថ្ងៃទី១៦ មីនា ២០០៣ ក្រុមតំណាងរាស្ត្រចំនួន១៣រូប មកពីគណបក្សសមរង្ស៊ី បានផ្ញើលិខិតថ្វាយព្រះមហាក្សត្រ សំណើសុំព្រះរាជប្រទានគោរម្យងារដល់សពលោក ជា វិជ្ជា ជា "វីរជនកម្មករ"។ សំណើនេះពុំទាន់ទទួលបានការឆ្លើយតបនៅឡើយទេ រហូតមកដល់ពេលនេះ។

១៣-ថ្ងៃ១៩ មីនា ២០០៤ ក្រុមតំណាងរាស្ត្រចំនួន១៨រូប មកពីគណបក្សសមរង្ស៊ីបានផ្ញើលិខិតជាលើកទី ២ ទៅក្រុមប្រឹក្សាធម្មនុញ្ញសំណើសុំឱ្យបកស្រាយនូវមាត្រាមួយចំនួន នៃរដ្ឋធម្មនុញ្ញ ដែលមានដូចខាងក្រោមនេះ:

១- មាត្រា១១៩ថ្មី ចែងពីការបង្កើតរាជរដ្ឋាភិបាល ដោយតម្រូវឱ្យសុំសេចក្តីទុកចិត្តពីរដ្ឋសភា។ តើសេចក្តីក្នុងមាត្រានេះ មានន័យយ៉ាងណាចំពោះការពុំអាចរកសេចក្តីទុកចិត្តពីរដ្ឋសភា ក្នុងការបង្កើតរាជរដ្ឋាភិបាលបាននោះ? តើមាត្រានេះមានន័យយ៉ាងណាដែរចំពោះរដ្ឋបាលគ្រប់គ្រងកិច្ចការប្រចាំថ្ងៃក្នុងកាលៈទេសៈរាំងស្ទះបែបនេះនោះ?

២- មាត្រា៩៦ មានន័យយ៉ាងណា បើនាយករដ្ឋមន្ត្រីប្រកាសមិនព្រមឆ្លើយនឹងសំណួររបស់អ្នកតំណាងរាស្ត្រ?

៣- មាត្រា៧៨ មានន័យយ៉ាងណា ចំពោះរដ្ឋសភាដែលមានអាណត្តិប្រាំឆ្នាំ ហើយនៅមិនទាន់មានរដ្ឋសភាថ្មីមកចូលកាន់តំណែងជំនួស?

៤- មាត្រា១០៣ ថ្មីមានន័យយ៉ាង ចំពោះសមាជិកព្រឹទ្ធសភា ដែលនៅពេលជាមួយគ្នាជាសមាជិករដ្ឋសភាផងនោះ?

ជាការឆ្លើយតបក្រុមប្រឹក្សាធម្មនុញ្ញបានចេញលិខិតលេខ០៥/០៤ កបធ សជណ ចុះថ្ងៃទី៧ មេសា ២០០៤ ជំរាបជូនទៅតំណាងរាស្ត្រទាំង១៨ រូបថា: *ដោយហេតុថា ពាក្យសុំបកស្រាយរបស់ឯកឧត្តម លោកជំទាវ មិនមែនជាពាក្យសុំបកស្រាយរដ្ឋធម្មនុញ្ញ សុទ្ធសាធទេនោះ ក្រុមប្រឹក្សាធម្មនុញ្ញសូមបង្វិលពាក្យរបស់ ឯកឧត្តម លោកជំទាវនេះ ត្រឡប់ជូនទៅឯកឧត្តម លោកជំទាវវិញ។*

១៤- ថ្ងៃទី២៥ មីនា ២០០៣ ឯកឧត្តម កែវ រ៉េមី តំណាងរាស្ត្រមណ្ឌលភ្នំពេញ មកពីគណបក្ស សមរង្ស៊ី បានផ្ញើលិខិតថ្វាយព្រះមហាក្សត្រ សំណើសុំព្រះរាជានុញ្ញាតិឱ្យអធិការកិច្ចនៃក្រសួងយុត្តិធម៌ ធ្វើការស៊ើប

អង្កេតក្នុងករណីដកតួនាទី នៃចៅក្រម និងព្រះរាជអាជ្ញាមួយចំនួន។ សំណើនេះពុំទាន់ទទួលបានការឆ្លើយតបនៅឡើយទេ រហូតមកដល់ពេលនេះ។

១៥- ថ្ងៃទី៣០ មីនា ២០០៣ ឯកឧត្តម កែវ រ៉េមី តំណាងរាស្ត្រមណ្ឌលភ្នំពេញ មកពីគណបក្ស សមរង្ស៊ី បានផ្ញើលិខិតទៅឯកឧត្តម គាត ឈន់ ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្នើសុំចាត់វិធានការទប់ស្កាត់ និងបញ្ឈប់តម្លៃប្រេងឥន្ធនៈ ដោយលើកឡើងថាតម្លៃប្រេងបច្ចុប្បន្ននេះឡើងខ្ពស់ ធ្វើឱ្យមានផលប៉ះពាល់ដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋយ៉ាងធ្ងន់ធ្ងរ។ ឯកឧត្តម គាត ឈន់ នៅថ្ងៃទី ១ មេសា ២០០៤ បានបដិសេធមិនធ្វើការឆ្លើយតបចំពោះលិខិតនោះទេ ដោយបានចាត់ទុកថានោះជា*លិខិតធម្មតា និងជាមតិមួយព្រោះលិខិតនោះ ពុំបានធ្វើមកតាមប្រធានស្ថាប័ននីតិបញ្ញត្តិឡើយ* (អត្ថបទរស្មីកម្ពុជាថ្ងៃទី២ មេសា ២០០៤)។

១៦- ថ្ងៃទី៥ មេសា ២០០៤ ឯកឧត្តម សុន ឆ័យ តំណាងរាស្ត្រមណ្ឌលភ្នំពេញ មកពីគណបក្ស សមរង្ស៊ី បានផ្ញើលិខិតទៅលោក តោ គិមស៊ាន ប្រធានមន្ទីរអប់រំខេត្តស្វៀមរាប សូមពិនិត្យករណីផ្លាស់អ្នកគ្រូ ម៉ី សុម៉ាឡា ពីជនបទមកបង្រៀននៅសាលាក្នុងទីប្រជុំជនខេត្តស្វៀមរាបតាមគោលការណ៍ក្រសួងអប់រំ។ សំណើនេះត្រូវបានទទួលការឆ្លើយតបតាមរយៈលិខិតលេខ៥៧៣ អយកខ.បលយ របស់មន្ទីរអប់រំខេត្តស្វៀមរាប ចុះថ្ងៃទី ២៣ មេសា ២០០៤។

១៧- ថ្ងៃទី៥ មេសា ២០០៤ ឯកឧត្តម កែវ រ៉េមី តំណាងរាស្ត្រមណ្ឌលភ្នំពេញ មកពីគណបក្ស សមរង្ស៊ី បានផ្ញើលិខិតទៅឯកឧត្តម ហុង ស៊ុនហួត ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសុខាភិបាល សំណើចាត់វិធានការ និងការណែនាំដល់គ្រូពេទ្យ និងបុគ្គលិកពេទ្យ ឱ្យយកចិត្តទុកដាក់ជាអាទិភាពក្នុងការជួយសង្គ្រោះអាយុជីវិតដល់អ្នកជំងឺ។ សំណើនេះពុំទាន់ទទួលបានការឆ្លើយតបនៅឡើយទេ រហូតមកដល់ពេលនេះ។

១៨- ថ្ងៃទី៦ មេសា ២០០៤ ឯកឧត្តម សុន ឆ័យ តំណាងរាស្ត្រមណ្ឌលភ្នំពេញ និងសកម្មជនសិទ្ធិមនុស្សមួយចំនួន បានផ្ញើលិខិតទៅលោក ហង់រ៉ូ វ៉ាកេន អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ សុំចេញដីកាចាប់ខ្លួនមេដឹកនាំ "ក្រុមកម្ពុជាប្រជាធិបតេយ្យ"ហៅ "ខ្មែរក្រហម" ឈ្មោះ នួន ជា ឈ្មោះ អៀង សារី និង ឈ្មោះ ខៀន សំផន ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ រួមទាំងចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរ ទៅលើច្បាប់មនុស្សធម៌អន្តរជាតិ និងទំលាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តជាតិដែលប្រទេសកម្ពុជាទទួលស្គាល់ ដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ១៧ មេសា ១៩៧៥ ដល់ថ្ងៃ៦ មករា ១៩៧៩។ សំណើនេះបានទទួលលិខិតឆ្លើយតបលេខ៨៦/០៤ គ្មានចុះកាលបរិច្ឆេទ ចុះហត្ថលេខាដោយ លោក ហង់រ៉ូ វ៉ាកេន អគ្គព្រះរាជអាជ្ញានៃ មហាអយ្យការសាលាឧទ្ធរណ៍ ដែលបានសុំឱ្យព្រះរាជអាជ្ញាតុលាការខេត្ត/ក្រុងចំនួនបីរួមមានខេត្តបាត់ដំបង បន្ទាយមានជ័យ និងស្វៀមរាប រៀបចំសំណុំរឿង ដើម្បីធ្វើការចោទប្រកាន់តាមច្បាប់។

១៩- ថ្ងៃ៦ មេសា ២០០៤ ឯកឧត្តម សុន ឆ័យ តំណាងរាស្ត្រមណ្ឌលភ្នំពេញ បានផ្ញើលិខិតទៅឯកឧត្តម អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា សូមចាត់មន្ត្រីតំណាង

ក្រសួងឱ្យចុះជួយដោះស្រាយការទាមទាររបស់បុគ្គលិកសណ្ឋាគារទាំង៦ ដែលកំពុងធ្វើកូដកម្មទាមទារលើប្រាក់កំរៃសេវានេះជាបន្ទាន់។

២០- ថ្ងៃទី៧ មេសា ២០០៤ ឯកឧត្តម ជ្រា សុចិន្តា តំណាងរាស្ត្រមណ្ឌលកណ្តាល មកពីគណបក្សសមរង្ស៊ី បានផ្ញើលិខិតទៅឯកឧត្តមសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សំណើសុំចាត់វិធានការបិទបនល្បែងស៊ីសងយូគីនៅផ្សារប៉ាហ៊ី(ហៅផ្សារសាមគ្គី) ស្ថិតនៅភូមិប៉ាហ៊ី សង្កាត់ប៉ៃលិន ខណ្ឌប៉ៃលិន ក្រុងប៉ៃលិន។ (សំណើនេះមិនបានទទួលការឆ្លើយតបទេ តែបនល្បែងបានបិទ ពីរ ឬបីថ្ងៃក្រោយពិធីចូលឆ្នាំខ្មែរ)។

២១- ថ្ងៃទី០៩ មេសា ២០០៤ តំណាងរាស្ត្រចំនួនប្រាំពីរ(៧)រូប មកពីគណបក្សសមរង្ស៊ីរួមមាន ឯកឧត្តម សុក ផេង តំណាងរាស្ត្រមណ្ឌលកំពង់ធំ ឯកឧត្តម ង៉ោ សុវណ្ណ ឯកឧត្តម ជ្រា សុចិន្តា តំណាងរាស្ត្រមណ្ឌលកណ្តាល ឯកឧត្តម ជា ប៊ូច តំណាងរាស្ត្រមណ្ឌលព្រៃវែង ឯកឧត្តម គួយ ប៊ុនរឿន តំណាងរាស្ត្រមណ្ឌលតាកែវ ឯកឧត្តម ហួរ វ៉ាន់ តំណាងរាស្ត្រមណ្ឌលភ្នំពេញ និងឯកឧត្តម នុត រំដួល តំណាងរាស្ត្រមណ្ឌលកំពង់ស្ពឺ បានផ្ញើលិខិតអំពាវនាវដល់ រាជរដ្ឋាភិបាលបង្កើតគណៈកម្មការឯករាជ្យមួយ ធ្វើការស៊ើបអង្កេតករណីមិនប្រក្រតីនៃប្រភពប្រាក់ចំណូលនេះ ដើម្បីបញ្ជាក់ថា ប្រាក់នៅក្នុងភាគហ៊ុនលោកជំទាវ ទេព បុប្ផាប្រសិទ្ធមិនពាក់ព័ន្ធនឹងអំពើពុករលួយណាមួយទេនោះ ហើយនិងដើម្បីបង្ហាញមតិសាធារណជាតិ និងអន្តរជាតិថា រដ្ឋាភិបាល ពិតជាមានឆន្ទៈប្រឆាំងអំពើពុករលួយដែលកំពុងរីករាលដាលយ៉ាងខ្លាំងក្លាក្នុងប្រទេសកម្ពុជាបច្ចុប្បន្ននេះ។ ករណីនេះគ្មានការឆ្លើយតបជាផ្លូវការពីស្ថាប័នមានសមត្ថកិច្ច។

២២- ថ្ងៃ១២ មេសា ២០០៤ លោកជំទាវ កែ សុវណ្ណរតន៍ តំណាងរាស្ត្រមណ្ឌលស្វាយរាប មកពីគណបក្សសមរង្ស៊ី បានផ្ញើលិខិតក្នុងនាមប្រជារាស្ត្រខ្មែរក្នុងខេត្តស្វាយរាប ក៏ដូចជាប្រជារាស្ត្រខ្មែរទូទាំងប្រទេសទាមទារ ឱ្យរដ្ឋាភិបាលចាំផ្ទះរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បញ្ឈប់ជាបន្ទាន់នូវការលក់ទីតាំងសាលាស្រុកស្វាយរាប ដោយខុសច្បាប់ គ្មានតម្លាភាព និងគ្មានការទទួលខុសត្រូវ។ ពុំទាន់មានការឆ្លើយតបនៅឡើយទេមកដល់ពេលនេះ។

២៣- ថ្ងៃទី២0 មេសា ២០០៤ ឯកឧត្តម កែវ រ៉ៃមី តំណាងរាស្ត្រមណ្ឌលភ្នំពេញ មកពីគណបក្សសមរង្ស៊ី បានផ្ញើលិខិតទៅឯកឧត្តម កែប ជុតិមា អភិបាលរាជធានីភ្នំពេញ សំណើឱ្យរៀបចំគំរោងធ្វើស្ពានថ្មឆ្លងកាត់ផ្លូវថ្ពល់ សំរាប់អ្នកថ្មើរជើងដើរឆ្លង។ សំណើនេះមិនបានទទួលលិខិតឆ្លើយតបជាផ្លូវការទេ ប៉ុន្តែ ឯកឧត្តម កែប ជុតិមា បានបញ្ជេញទស្សនៈគាំទ្រចំពោះសំណើនេះតាមរយៈប្រព័ន្ធផ្សព្វផ្សាយ។

២៤- ថ្ងៃទី២២ មេសា ២០០៤ ឯកឧត្តម កែវ រ៉ៃមី តំណាងរាស្ត្រមណ្ឌលភ្នំពេញ មកពីគណបក្សសមរង្ស៊ី បានផ្ញើលិខិតទៅឯកឧត្តមបណ្ឌិត ម៉ុក ម៉ារ៉ែត រដ្ឋមន្ត្រីក្រសួងបរិស្ថាន សំណើសុំចុះត្រួតពិនិត្យ និងមានវិធានការជាបន្ទាន់ ចំពោះការធ្វើអាជីវកម្មរ៉ែមាស នៅស្រុកសំបូរ ខេត្តក្រចេះ។ សំណើនេះមិនបានទទួលលិខិតឆ្លើយតបជាផ្លូវការទេ។

២៥- ថ្ងៃទី២២ មេសា ២០០៤ ក្រុមតំណាងរាស្ត្រ មកពីគណបក្សសមរង្ស៊ី បានចេញសេចក្តីថ្លែងការណ៍សាធារណៈមួយព្រមានដល់អ្នកនិវិយោគដេញថ្លៃកសាង និងគ្រប់គ្រងទំនប់បូកគោ ថាជាដំណើរការខុសច្បាប់ និងមិនត្រូវបានទទួលស្គាល់ដោយរដ្ឋាភិបាលថ្មី។ ពុំទាន់មានប្រតិកម្មពីស្ថាប័នណាមួយនៅឡើយទេមកដល់ពេលនេះ។

២៦- ថ្ងៃទី២៦ មេសា ២០០៤ ឯកឧត្តម សុក ផេង តំណាងរាស្ត្រមណ្ឌលកំពង់ធំមកពីគណបក្សសមរង្ស៊ីបានផ្ញើលិខិតទៅឯកឧត្តម អគ្គលេខាធិការអង្គការសហប្រជាជាតិ កូហ្វីអាណាន់ សំណើសុំអន្តរាគមន៍ជួយរកយុត្តិធម៌ ជូនលោកស្រី អ៊ុង សាន សូជី និងប្រជាជនភូមា។

២៧- ថ្ងៃ២៨ មេសា ២០០៤ ឯកឧត្តម សុន ឆ័យ តំណាងរាស្ត្រមណ្ឌលភ្នំពេញ មកពីគណបក្សសមរង្ស៊ី បានផ្ញើលិខិតទៅឯកឧត្តម ប៊ិន ឈិន ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ស្នើសុំនូវគំរូបែបបទនៃការសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយរដ្ឋធម្មនុញ្ញតាមបែប "ត្រូវនឹងទម្រង់ច្បាប់"។

២៨- ថ្ងៃទី២៩ មេសា ២០០៤ ឯកឧត្តម សុក ផេង តំណាងរាស្ត្រមណ្ឌលកំពង់ធំ មកពីគណបក្សសមរង្ស៊ី បានផ្ញើលិខិតទៅលោក ស្នងការនគរបាល ខេត្តកំពង់ធំ សំណើចាត់វិធានការដាក់វិន័យរដ្ឋបាលដល់ប្រធាននគរបាលប៉ុស្តិ៍រដ្ឋបាលពាមបាង ស្រុកស្ទោង ខេត្តកំពង់ធំ ដែលមិនបានចាត់វិធានការឃាត់ខ្លួនឈ្មោះដែលបានវាយមកលើជនរងគ្រោះ តាមរយៈការប្តឹងផ្តល់។ ពុំមានការឆ្លើយតបនៅឡើយទេមកដល់ពេលនេះ។

២៩- ថ្ងៃ៣0 មេសា ២០០៤ ឯកឧត្តម សុន ឆ័យ តំណាងរាស្ត្រមណ្ឌលភ្នំពេញ មកពីគណបក្សសមរង្ស៊ី បានផ្ញើលិខិតទៅឯកឧត្តម NONG Duc Manh អគ្គលេខាធិការបក្សកម្មុយនីស្តវៀតណាម ឱ្យធ្វើការអន្តរាគមន៍ជាបន្ទាន់ចំពោះករណីពួកកុលសម្ព័ន្ធភ្នំវៀតណាម។ ពុំមានការឆ្លើយតបនៅឡើយទេមកដល់ពេលនេះ។

៣0- ថ្ងៃ៣0 មេសា ២០០៤ សមាជិកសភាគណបក្សសមរង្ស៊ី បានចេញសេចក្តីថ្លែងការណ៍ពត៌មានមួយសំដែងនូវការសោកស្តាយ ស្តីពីការហាមឃាត់ការប្រារព្ធទិវាពលកម្មរបស់សហជីពកម្មករ និងគ្រូបង្រៀនចំនួនបួនដែលបានស្នើសុំទៅអភិបាលក្រុងភ្នំពេញ កាលពីថ្ងៃទី ២៩ មេសា ២០០៤ ដើម្បីធ្វើការហែក្បួនតាមវិថីមួយចំនួនក្នុងទីក្រុង និងធ្វើមីទ្ទិញនៅបរិវេណសួនច្បារមុខវត្តបុទុមវត្តី ដែលបំរាមនេះបានរំលោភទៅស្មារតីរដ្ឋធម្មនុញ្ញដែលបានផ្តល់សិទ្ធិសេរីភាពក្នុងការសំដែងមតិ និងការជួបប្រជុំដល់ពលរដ្ឋគ្រប់រូប។

គួរធ្វើការកត់សំគាល់ផងដែរថា ខុមហ្វ្រែល ពុំដែលបានឃើញ ឬទទួលសេចក្តីស្នើច្បាប់ ការលើកជាការព្រួយបារម្ភ ការផ្ញើលិខិតអន្តរាគមន៍ សុំចាត់វិធានការ សុំការបកស្រាយច្បាប់នានារបស់អ្នកតំណាងរាស្ត្រមកពីគណបក្សប្រជាជនកម្ពុជា និងគណបក្សហ៊្វុនស៊ិនប៉ិចនៅឡើយទេ រហូតមកដល់ពេលនេះ។

<u>ឧបសម្ព័ន្ធ ៤:</u> របាយការណ៍ស្តីពីការគំរាមកំហែង បំភិតបំភ័យ និងឃាតកម្ម

១. ករណីគំរាមកំហែងលើតំណាងរាស្ត្រ

មានពត៌មាន ស្តីពីករណីគម្រាមរកសម្លាប់ដល់តំណាងរាស្ត្រចំនួន៥រូប គណបក្សហ៊ុនស៊ិនបុិចពីររូប គណបក្សសមរង្ស៊ីបីរូបដែលរួមមាន:

១- ក្នុងខែមករា ២០០៤ មានករណីគម្រាមរកសម្លាប់ដល់តំណាងរាស្ត្រគណបក្សនយោបាយ និងសកម្មជនសិទ្ធិមនុស្សចំនួនប្រាំរូប តាមរយៈបញ្ជីខ្មៅដែលត្រូវផ្សព្វផ្សាយជាសាធារណៈ ដែលរួមមាន:

- ស្តេចក្រុមឃុន នរោត្តម សិរីវុឌ្ឍ ព្រះអគ្គលេខាធិការគណបក្សហ៊ុនស៊ិនបុិច តំណាងរាស្ត្រមណ្ឌលកណ្តាល។
- ឯកឧត្តម សម រង្ស៊ី ប្រធានគណបក្សសមរង្ស៊ី តំណាងរាស្ត្រមណ្ឌលកំពង់ចាម
- ឯកឧត្តម អេង ឆៃអៀង អគ្គលេខាធិការគណបក្សសមរង្ស៊ី តំណាងរាស្ត្រមណ្ឌលបាត់ដំបង
- លោក កឹម សុខា ប្រធានមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (មិនមែនជាតំណាងរាស្ត្រទេ)
- លោក រ៉ុង ឈុន ប្រធានសមាគមគ្រូបង្រៀនឯករាជ្យ (មិនមែនជាតំណាងរាស្ត្រទេ)

ករណីនេះជាមូលហេតុ បណ្តាលឱ្យមានការប្តឹងផ្តល់គ្នារវាងសម្តេច ហ៊ុន សែន និងឯកឧត្តម សម រង្ស៊ី។

២- ថ្ងៃទី១៨ កុម្ភៈ ២០០៤ មានករណីគម្រាមប្រមាថរកសម្លាប់តំណាងរាស្ត្រគណបក្សហ៊ុនស៊ិនបុិច តាមរយៈសារអេឡិចត្រូនិកដែលផ្ញើដោយជនអនាមិកទៅ ឯកឧត្តម លឺ ឡាយស្រេង ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពត៌មាន ដែលមានខ្លឹមសារថា: *"អញប្រាប់ហ្អែងឱ្យដឹង ហ្អែងមានជីវិតរស់ត្រឹមថ្ងៃទី២៨ កុម្ភៈ ២០០៤ ប៉ុណ្ណោះវែលាម៉ោង៧ល្ងាចជាកំហិត ពីអញជាឱ្ហែង។"*

៣- ថ្ងៃ២ មីនា ២០០៤ មានពត៌មានការអង្កេតពេញលេញទៀតពីសំណាក់ឯកឧត្តម សុខ ផេង តំណាងរាស្ត្រមណ្ឌលកំពង់ធំ គណបក្សសមរង្ស៊ី ស្តីពីករណីបំភិតបំភ័យបង្កឡើងដោយជនប្រដាប់អាវុធ។ ហេតុការណ៍នេះកើតឡើង ក្រោយពីឯកឧត្តម សុខ ផេង និងតំណាងរាស្ត្រគណបក្សសមរង្ស៊ីចំនួន ៤រូបទៀត ដាក់ពាក្យប្តឹង ឯកឧត្តម សូ ឃុន រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៏ និងទូរគមនាគមន៏ ពីបទស៊ីសំណូក និងក្រុមហ៊ុនម៉ូប៊ីថែល ពីបទសូកប៉ាន់ ទៅតុលាការក្រុងភ្នំពេញកាលពីថ្ងៃទី១ មីនា ២០០៤។

២. ករណីគំរាមកំហែង និងឃាតកម្មលើសកម្មជនគណបក្សនយោបាយ

យោងតាមរបាយការណ៍ពីបណ្តាញខុមហ្វ្រែល និងសមាគមអាដហុកខេត្ត/ក្រុងទាំង២៤ និងអង្គការសិទ្ធិមនុស្សនានា ក្នុងអំឡុងគិតចាប់តាំងពីខែតុលា ២០០៣ ដល់ខែមេសា ២០០៤ មានករណីឃាតកម្មពាក់ព័ន្ធសកម្មជនគណបក្សនយោបាយចំនួន១៧ករណី សំលាប់មនុស្សចំនួន១៩នាក់ ក្នុងនោះរួមមាន សកម្មជនគណបក្សសមរង្ស៊ីចំនួន១៣នាក់ គណបក្សហ៊្វុនស៊ិនប៉ិចចំនួនពីរនាក់ គណបក្សប្រជាជនកម្ពុជាចំនួនពីរនាក់។ ក្នុងចំណោមករណីឃាតកម្មទាំងនេះ ភាគច្រើនបង្កឡើងដោយជន ប្រដាប់អាវុធមិនស្គាល់អត្តសញ្ញាណ។ ទន្ទឹមនឹងនេះ ក៏នៅមានករណីគំរាមកំហែងទៅលើសកម្មជនគណបក្សនយោបាយចំនួន១៤ករណី ទៅលើសកម្មជនគណបក្សសមរង្ស៊ីចំនួន ៨ករណី ទៅលើសកម្មជន គណបក្សហ៊្វុនស៊ិនប៉ិចចំនួន៦ករណី និងទៅលើសកម្មជនគណបក្សហង្សដារ៉ាចលនាប្រជាធិបតេយ្យចំនួន១ករណី។ ករណីគំរាមកំហែងទាំងនេះ ច្រើនប្រព្រឹត្តឡើងដោយអាជ្ញាធរ និងកងកម្លាំងប្រដាប់អាវុធមូលដ្ឋាន។ ហើយករណីភាគច្រើន សមត្ថកិច្ចពុំដែលវែកមុខរកជនល្មើសប្រព្រឹត្តបទល្មើស ឬឃាតករឃើញទេ។

២.១. តារាងករណីឃាតកម្មលើសកម្មជនគណបក្សនយោបាយ គិតចាប់តាំងពីខែ តុលា ឆ្នាំ២០០៣ រហូតដល់ ខែមេសា ឆ្នាំ ២០០៤

I>r	eBIevIa ngTkEng	CnrgeRKaH	KNbkS	CneIs	BBNnæhtkarN	vFankarrbssmtkc	ITpI
១	០៥/១០/០៣ ភូមិ វល្លិ៍យាវ ឃុំកំពង់ស្វាយ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ	ថន ឌៀវ ជាសមាជិកក្រុមប្រឹក្សាឃុំមកពីគណបក្សសមរង្ស៊ី	សមរង្ស៊ី	ជនមិនស្គាល់មុខ	នៅវេលាម៉ោងប្រមាណជា ២ រសៀល សាកសពជនរងគ្រោះត្រូវបានគេប្រទះឃើញនៅក្បែរផ្លូវថ្នល់ ចម្ងាយ៣គីឡូម៉ែត្រពីផ្ទះរបស់ខ្លួន។ ជនរងគ្រោះត្រូវបានគេសម្លាប់ដោយកាប់និងខ្វៃ ឱ្យដាច់ជាកំណាត់ៗ ។	កំពុងស៊ើបអង្កេត	

I>r	eBIevIa ngTkEng	CnrgeRKaH	KNbkS	CneIs	BBNnæhtkarN	vFankarrbssmtkc	ITpI
២	១៣/១០/០៣ ភូមិអណ្តូងដៃ ឃុំព្រែកក្របៅ ស្រុកកងមាស ខេត្តកំពង់ចាម	ស៊ឹម ម៉ូវ និង ក្រុមគ្រួសារ ជា បេក្ខភាពសមាជិក ក្រុមប្រឹក្សាឃុំលំដាប់ លេខរៀងទី១៤ មកពី គណបក្សសមរង្ស៊ី	សមរង្ស៊ី	ជនមិនស្គាល់មុខ	នៅវេលាម៉ោង ៧:១៥នាទី ជនមិនស្គាល់មុខបានធ្វើការលួចវាយប្រហារ ដោយគ្រាប់បែកដៃទៅលើលំនៅស្ថានរបស់ជនរងគ្រោះបណ្តាលឱ្យស្លាប់ម្នាក់ និងរបួស ៤នាក់ : ១-ស៊ឹម ម៉ូវ (ស្លាប់) ២-សេង ភាព អាយុ ៤២ឆ្នាំ ជាប្រពន្ធជនរងគ្រោះ ៣-ស៊ឹម ស្រី អាយុ១០ឆ្នាំ ៤-ស៊ឹម ណារិន អាយុ ០៥ឆ្នាំ ៥-ឆែ អៀង អាយុ០២ឆ្នាំ	កំពុងស៊ើបអង្កេត	
៣	១៨/១០/០៣ ផ្ទះលេខ ២៧អា ផ្លូវលេខ ៤៧ហ្សិត សង្កាត់ទួលទំពូង២ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ	ជួរ ជេត្ថារិទ្ធ ភេទប្រុស អាយុ៣៧ឆ្នាំ ជាអ្នក និពន្ធអត្ថបទពត៌មាន ឱ្យវិទ្យុតាព្រហ្ម និងជា អនុប្រធានអធិការកិច្ច កិច្ចការរដ្ឋបាលក្រសួង មហាផ្ទៃ (ឃាតកម្ម)	ហ៊ុនសុិន ប៊ិច	ជនមិនស្គាល់មុខ	នៅវេលាម៉ោង ៨:១៥នាទី ជនល្មើសប្រដាប់ដោយអាវុធកាំ៥៩មួយដើម បានជិះម៉ូតូម៉ាកអឺមដេ ១២៥ សេរី២០០៣ មួយគ្រឿង បានបាញ់ប្រហារទៅលើក្បាលជនរងគ្រោះមួយគ្រាប់ ខណៈពេលដែលជនរង គ្រោះចុះពីក្នុងរថយន្តដើរសំដៅទៅកាន់ទីស្នាក់ការផ្សាយរបស់វិទ្យុតាព្រហ្ម ស្ថិតនៅតាមដងផ្លូវលេខ ៤៧២ បណ្តាលឱ្យស្លាប់ភ្លាមៗនៅនិងផ្ទះកឈាម ។	កំពុងស៊ើបអង្កេត	
